## ឃ- ពាក្យសួរ

តើដោយប្រភេទណា ឧបាយណា ប្រទេសនីមួយ ៗ នឹងចម្រើនបាន ? អ្នកយល់ដូចម្តេចខ្លះ ក្នុងរឿងនេះ ?

---

## មេរៀនទី ៦៨

### គុណទោសនៃអាហារ

ជីវិតរស់នៅ ឥតពេលសំដៅ ក្រៅពីអាហារ
បាយត្រីសាច់ស៊ុត បន្លែបង្ការ ផ្លែឈើសុទ្ធជា
អាហារគ្រប់ប្រាណ ៗ បាយជាព្រះមេ ប្រសើរជាងគេ
អាហារសន្តាន ខ្មែរនឹងចិនជ្វា យួនចាមចង់បាន
ព្រោះអាចយោងប្រាណ ឲ្យបានរស់នៅ ៗ បន្លែគ្រឿងស្ល
បន្ទាប់បន្ត អំពីបាយទៅ ត្រូវតែជៀសវាង
បន្លែដែលនៅ ព្រោះតែស៊ីទៅ ច្រើនក្តៅឈឺមួល ៗ
ផ្លែឈើកំដា ចំណីសោភា ស៊ីទៅបានស្រួល
ផ្អែមហើយឈ្ងុយឆ្ងាញ់ ចិត្តចង់រំដួល មនុស្សយើងជ្រើមជ្រួល
ចង់បរិភោគក្រៃ ៗ បន្លែត្រូវវៀរ កុំប៉ះពារ
ផ្លែឈើណាខ្ចី ឬផ្លែឈើទុំ ហួសហេតុពេកក្រៃ

ព្រោះជាបំណាំ　　នាំកើតរោគា ៗ　　ជម្ងឺបុកចាប់
អាសន្នរោគស្លាប់　　កើតព្រោះផលា　　នៅខួបណ្ដាល
កើតរោគគ្រប់គ្នា　　ត្រូវតែយើងវៀរ　　បៀសវាងឲ្យឆ្ងាយ ៗ
ផ្លែឈើទុំហួស　　នេះក៏ជាគ្រោះ　　នាំកើតអន្តរាយ
ឈឺក្នុងពោះវៀន　　នឹងក្រពះបាយ　　យូរទៅផ្សព្វផ្សាយ
សព៌ាង្គកាយផង ៗ
ក្មេងៗសាប់ខ្ទី　　ចូលចិត្តតែស៊ី　　នំស្ករពេកហោង
ចាស់ៗដែលថែ　　ត្រូវតែគ្រប់គ្រង　　កុំតាមបំណង
ចិត្តវាប្រាថ្នា ៗ

(ស្រង់ពីទស្សនាវដ្ដីសិក្សាឆ្នាំ១៩៥២)

## ក- សព្ទពន្យល់

សុិត = (ម. ថ. សុទ្ធ) ពង

បង្ការ = ពាក្យបរិវាររបស់បន្លែ - បន្លែបង្ការ

សោភា = ល្អប្រសើរ

ផលា = (ម. ថ. ផល់ឡា) ផ្លែឈើ

ផ្សព្វផ្សាយ = ផ្សាយការប៉ះពាល់ត្រូវ

សព៌ាង្គកាយ= (ម.ថ.សព៌ាង្គ) កន៌កាយទាំងមូល

## ១– គំនិត

អាហារជាគ្រឿងប្រើបាច់សំរាប់ទ្រទ្រង់ជីវិត ឲ្យរស់នៅ; មនុស្សម្នាក់ ១ ត្រូវការបរិភោគអាហារឲ្យមានកំណត់...

## គ– សុភាសិត

យើងបរិភោគអាហារដើម្បីឲ្យរស់ជីវិត;

មិនមែនរស់ជីវិតដើម្បីស៊ី...

## ឃ– ពាក្យសួរ

អាហារអ្វីខ្លះ ដែលអាចទ្រទ្រង់ជីវិតយើងឲ្យរស់នៅបាន ? អាហារបែបណាខ្លះ ដែលអាចបណ្ដាលឲ្យយើងមានរោគឈឺចុកចាប់បាន ? យោបល់យល់ឃើញរបស់អ្នកដូចម្ដេចខ្លះ ?

---

## មេរៀនទី ៦៩ •

## រុក្ខជាតិនិងតិណជាតិ

| | | |
|---|---|---|
| រុក្ខជាតិឈើព្រៃ | យើងអាចវិនិច្ឆ័យ | ពិនិត្យឲ្យច្បាស់ |
| ថាមានប្រយោជន៍ | ដល់មនុស្សណាស់ | ដូចយ៉ាងធ្វើផ្ទះ |

| | | |
|---|---|---|
| ឬកិច្ចច្រើនទៀត ៗ | ធ្វើថ្នាំក្តីណា | កែរោគសះជា |
| ព្រោះតែរុក្ខជាតិ | យកជាសែមក | ធ្វើការបានទៀត |
| ឬតិណជាតិ | គឺស្មៅបានខ្លះ ៗ | ឬសស្រូបទឹកភ្លៀង |
| តាមលោកបានផ្ទៀង | ឃើញច្បាស់ជាក់ណាស់ | ទឹងអាចបង្ខាំង |
| ទឹកហូរហោស | ជំនន់លិចផ្ទះ | ក៏អាចទាំងបាន ៗ |
| ជួរបេះគួរគិត | រក្សាជីវិត | នៃព្រៃកល្យាណ |
| ឈើណាធំ ៗ | កែរ្យកុំច្រើនមាន | កុំកាប់ទន្ទ្រាន |
| ទុកប្រើយើនយូរ ៗ | | |

( ស្រង់ពីទស្សនាវដ្តីសិក្សា ១៩៥២ )

## ក – សព្ទពន្យល់

រុក្ខជាតិ = ជាតិឈើ

តិណជាតិ = (ម.ប.តិៈណៈ:–) ជាតិស្មៅ

ព្រៃកល្យាណ = (ម.ប. កល់-ល-យ៉ាន) ព្រៃល្អ

## ខ – គំនិត

យើងមិនត្រូវកាប់ឆ្ការព្រៃឈើតាមទំនើងចិត្ត ត្រូវរក្សាព្រៃឲ្យបានល្អទុកប្រើបានយូរ ៗ

## គ – ពាក្យសួរ

ឈើព្រៃមានប្រយោជន៍ឲ្យយើងដូចម្តេច? ចុះឯស្មៅវិញមានប្រយោជន៍ដូចម្តេចខ្លះ?

---

# មេរៀនទី ៧០

## យកមិត្តអាក្រក់នាំឲ្យមានទុក្ខ

បើចង់ចងមិត្តនឹងអ្នកណា ត្រូវមើលកិរិយាឲ្យប្រពៃ
បើសង្កេតទៅមិនគប្បី ប្អូនកុំមេត្រីយកជាមិត្ត ។
ទោះអ្នកប្រព្រឹត្តល្អយ៉ាងណា ឃើញមនុស្សស្នេហាមិនមានគិត
រាប់អានពានលើមនុស្សទុច្ចរិត នាំឲ្យខូចចិត្តមានទុក្ខភ័យ ។
ដូចជាឈ្មោះប្រាក់អ្នកសុចរិត យកមិត្តនឹងហ្លួនមនុស្សព្រៃ
ហ្លួនទៅប្លន់ទ្រព្យអ្នកដទៃ ប្រាក់មិនដឹងអីនៅតែផ្ទះ ។
ប្លន់រួចហ្លួនចូលជ្រកនៅ ក្រម្ការទៅស៊ើបដឹងច្បាស់
នាំគ្នាចាប់យ៉ាងរហ័ស បានទៅប្រទះហ្លួនផ្ទះប្រាក់ ។
ចាប់ទាំងប្រាក់ឲ្យផ្ទះហ្លួននៅ ដាក់ខ្នោះនាំទៅទាំងពីរនាក់
នេះគឺមិនពិនិត្យឲ្យជាក់ យកជាមិត្តភក្តិមានទុក្ខក្រោយ ។

( ស្រង់ពីកិច្ចសិក្សាឆ្នាំ ១៩៣៦ )

## ក- សព្ទពន្យល់

មិត្ត= (ម. ថ. មិត) អ្នកដែលរាប់អានគ្នាជិតដិត. សំឡាញ់

មិត្តមានពីរយ៉ាងគឺ: កល្យាណមិត្ត និងបាបមិត្ត ។

មេត្រី= សេចក្ដីរាប់រក, រាប់អាន ។

ទុច្ចរិត= (ម. ថ. ទុច-ចៈរិត) ដំណើរប្រព្រឹត្តអាក្រក់, ដោយកាយ, វាចា, ចិត្ត ។

កម្មករ= (ម.ថ. កំមៈការ) អ្នកធ្វើការ; ងារក្នុងដំណែងរកដការ ។

## ១- គំនិត

មុននឹងចងមិត្តនឹងអ្នកណា ត្រូវមើលកិរិយាឲ្យប្រពៃ សឹមសេពគប់ចូល ។

" អ្នកណាមិនលះបង់មិត្ត ក្នុងគ្រាមានទុក្ខ ក្នុងគ្រាអន្ត " រាយ ក្នុងគ្រាទុរ្ភិក្ស ក្នុងគ្រាព្រួចលាចល ក្នុងទ្វារព្រះ " រាជា និងនៅព្រៃស្មសាន, អ្នកនោះលោកហៅថាផៅពង្ស " ។

ប៉ាង - ខាត់ (ស្រីហិតោបទេស)

## គ- សុភាសិត ឬ សីលធម៌

" ធម្មជាតិទុជ៌ន កុំចង់សម្ពន្ធ យោងយកជាគ្នា
" បីដូចធ្យូងក្តៅ រលាកអង្គា ទោះរលត់ក៏
" សឹងជាប្រឡាក់ ។ ពាក្យពេចន៍លែបខាយ
" ផ្អែមល្ហែមស្រស់ស្រាយ ទឹកឃ្មុំដៀងជាក់
" ក្នុងចិត្តពិសពុល សាហាវអបលក្ខណ៍
" កុំគប់រួមរ័ក្ស ស្មោះស្ម័គ្រមូលមិត្ត ,, ។

លោកហេង - យ៉ាន់ (ប្រជុំរឿងល្បើក)

## ឃ- ពាក្យសួរ

យើងដឹងមិត្តល្អ ឬ អាក្រក់បានដោយប្រការណា ខ្លះ?

ដូចម្តេចបានជាប្រាក់ជាអ្នកសុចរិត ត្រូវពដការចាប់វិញ? យោបល់យល់ឃើញរបស់អ្នកដូចម្តេច ។

---

## មេរៀនទី ៧១

### សិប្បិយការកើតឡើងពីជាតិសត្វ

ឯសាសន៍ខ្មែរឥឡូវនេះ ច្រើនមានអ្នកចេះត្បាញប្រសើរ
ធ្វើអំពីសូត្រល្អគ្រាន់បើ គេពប់អានប្រើជាងឯទៀត ។

គេយកសូត្រមកធ្វើជាមួង　　ធ្វើហូលទាំងពួងនឹងព្រែលាក
ព្រែផ្កាក្រម៉ាសារុងទៀត　　ឯហូលចងគៀតមានគោមផង ៗ
បំណែកឯខាងអ្នកធ្វើសូត្រ　　ខំប្រូតមនឲ្យនាងស៊ុំហោង
ដល់នាងសម្បុរលឿងជាម្ដង　　គេក្រងឫស្សីធ្វើសម្រាស់ ៗ
រួចចាប់ដង្កូវនាងដាក់ទៅ　　គ្នាខំប្រឹងនៅការខ្វាស ៗ
ខំធ្វើសំបុកលើសម្រាស់　　ការព័ទ្ធរហាស់ធាប់ណាស់សា ៗ
ទើបគេដាំទឹកថ្វាងឲ្យពុះ　　យកសំបុកទៅដាក់ត្រៀបត្រា
រវៃបានសរសៃកាលណា　　ដោះហាលហើយសាយកទៅទុក ៗ

(ស្រង់ពីកិច្ចសិក្សាឆ្នាំ១៩៣៦)

## ក — សព្ទពន្យល់

គោម= ក្រឡាប្អូនជ្រុង, ឬមានក្រឡាសណ្ឋានផ្សេងៗ ដែលមាននៅសំពត់...

## ខ — គំនិត

ការចិញ្ចឹមនាង នឹងត្បាញហូលជាមួង ជារបរដ៏សំខាន់របស់ខ្មែរតាំងពីបុរាណកាលរហូតមកដល់សព្វថ្ងៃ ៗ

## គ — ពាក្យសួរ

ស្រីខ្មែរពីដើមនឹងស្រីខ្មែរឥឡូវ តើខុសគ្នាដូចម្ដេចខ្លះ ក្នុងការត្បាញ

សំពត់ បិញ្ចឹមនាង? ធ្វើដូចម្ដេចខ្លះ ដើម្បីបិញ្ចឹមនាងឲ្យបានល្អ? សព្វថ្ងៃនេះ ខ្ញុំនិយមបិញ្ចឹមនាងណាស់ឬទេ? ពីព្រោះអ្វី?

---

## មេរៀនទី ៣២

### វេជ្ជបុរសយ៉ាងបំណាន

| | | |
|---|---|---|
| កាលណោះមានគ្រូម្នាក់ | យ៉ាងឯកអគ្គគុណប័ក្សពេទ្យ | |
| កិត្តិយសខ្ពស់ត្រដែត | គេបដិសេធលោកពុំបាន | ៗ |
| ថ្ងៃមួយលោកអាពាធ | ជម្ងឺព្យាធិកើតក្នុងប្រាណ | |
| ឥតបានធូរស្រាកស្រាន្ត | នៅសម្រាន្តផ្ដាំសិស្សថា | ៗ |
| ជីវៈខ្ញុំអស់ហើយ | ពុំយូរឡើយអ្នកពល់គ្នា | |
| នៅឲ្យបានសុខា | ខ្ញុំសូមលាទៅបរលោក | ៗ |
| តែបើខ្ញុំក្ស័យទៅ | គ្រូបីទុកនៅក្នុងលោក | |
| គ្រាន់នឹងព្យាបាលរោគ | យ៉ាងពិសេសឥតគណនា | ៗ |
| លោកថាតែប៉ុណ្ណោះ | ក៏ឈប់ស្ទុះលែងចរចា | |
| ពួកសិស្សស្រងឹមថា | ក្រែងអាត្មាជាគ្រូដឹង | ៗ |
| លុះលោកមានកម្លាំង | លោកក៏តាំងពោលដោយប្រឹង | |
| ខ្ញុំប្រាប់បួរអ្នកដឹង | គ្រូបីហ្នឹងដូច្នេះថា | ៗ |

ទី ១ ការសំអាត ប្រឹងសង្អាតដោយឧស្សាហ៍
ផុសខាត់អង្គអាត្មា ទឹងសម្លៀកបំពាក់ផង ។
ទីពីរនោះសោតទៀត ប្រមាណត្បៀតកុំសៅហ្មង
អាហារភោជនផង តាមបំណងពុំបានឡើយ ។
ទីបីហាត់ខ្លួនប្រាណ នោះទើបបានសុខជាត្រើយ
ធាតុបួនស្មើស្រួលហើយ រោគធូរស្បើយកើតពុំបាន ។
បីនេះគ្រូសំខាន់ បើប្រកាន់ទឹងសុខប្រាណ
មើលរោគបានក្សេមក្សាន្ត ជំនួសប្រាណខ្ញុំបាត់ទៅ ។

(ស្រង់ពីទស្សនាវដ្ដីសិក្សាឆ្នាំ១៩៥២)

## ក- សព្ទពន្យល់

វេជ្ជបុរស= (ម.ថ. វេ-ជ:-) បុរសជាពេទ្យ–គ្រូពេទ្យ ។

អគ្គ= (ម.ថ. អាក់-គ:) ប្រសើរ

បក្ស= (ម.ថ. ប៉ាក់)ពួក , ក្រុម

បដិសេធ= ម.ថ. ប.ដិ.សែត) លើកលែង–លែងរាប់អាន

ព្យាធិ= (ម.ថ. ព្យាត– ) ជម្ងឺ, រោគ, អាពាធ

ជីវិៈ = (ម.ថ. ជី-វ៉ក ) ការរស់នៅ-ជិតនៅ

បរលោក= ( ម.ថ.ប - ឡោក ) លោកខាងមុខ

ក្សយ = ការអស់ជីវិត - វិនាសជីវិត ។

## ខ- គំនិត

បើយើងចង់បានសេចក្ដីសុខ ត្រូវប្រព្រឹត្តតាមដម្បូន្មានខាងក្រោមនេះ :

ទី ១ – ការសំអាត

ទី ២ – ការប្រមាណក្នុងអាហារទឹង...

ទី ៣ ការហាត់ខ្លួនប្រាណ

## គ- សុភាសិត

" សត្រូវក្លាកាច បំផុតនៅព្យាធិ "

## ឃ- ពាក្យសួរ

វេជ្ជបុរសមានប្រសាសន៍ទៅកាន់ពួកកូនសិស្ស លោកថាដូចម្ដេចខ្លះ? អ្នកណាជាគ្រូពេទ្យ? អ្នកយល់ឃើញដូចម្ដេចខ្លះ ក្នុងមេរៀននេះ?

---

# មេរៀនទី ២៣

## ទោសនៃសុរា (តបប់)

រាសដៃជើង ឡើងជំនោរ ដោរបំណាច់

| | | | |
|---|---|---|---|
| អ្នកចាក់កាប់ | អាន់តែស្លាប់ | ឥតសោកស្ដាយ | |
| ឈប់ស្គាល់កូន | ទៅប្រពន្ធ | ឪពុកម្ដាយ | |
| ហ៊ានមើលងាយ | ពាយដេរលោក | អ្នកមានគុណ | ៗ |
| ប្រឡំឪ | ថាជាពួក | ម៉ាកកៀនផឹក | |
| ឃើញមុខម៉ែ | បែរជាទឹក | ថាប្រពន្ធ | |
| ត្រង់មិនគួរ | ថាជាគួរ | បាបជាបុណ្យ | |
| ទោសជាគុណ | បុណ្យជាបាប | សាបជាប្រៃ | ៗ |
| ការប្រមឹក | នាំប្រមាទ | ខាតកុសល | |
| នាំអំពល់ | ដល់អំពើ | ប្រសើរក្រៃ | |
| នាំបានទុក្ខ | បុកម្នេញ | ពេញដួងថៃ | |
| នាំចង្រៃ | នាំបង្អាស | ប្រាសព្រាត់គ្នា | ៗ |
| នាំថោកទាប | ត្រកូលញាតិ | ជាតិផៅពង្ស | |
| នាំឲ្យល្ងើ | ភ្លើឲ្យល្ងង់ | ឆ្កួតពាលា | ៗ |
| នាំគេខ្ពើម | រអើមស្អប់ | គេនិន្ទា | |
| នាំវេរា | ចងពៀរគ្នា | ជាអន្លង់ | ៗ |
| នាំចាក់កាប់ | នាំជាប់គុក | នរកគោក | |
| នាំឲ្យសោក | វិយោគសៅ | យំសស្រេន | |

| | | |
|---|---|---|
| នាំអន់អ័ប្ប | យ៉ាប់កេរ្តិ៍ឈ្មោះ | យូរអង្វែង |
| នាំឲ្យក្មេង | លែងកោតក្រែង | លែងគោរព |
| ការប្រមឹក | ជាប្រមុខ | ទុក្ខបច្ចុប្បន្ន |
| ឃើញស្រ្វពន់ | ទាន់ហន់ណាស់ | គួរតែឈប់ |
| ងប់រលោក | ដោះទៅកាន់ | ទុគ្គតិភព |
| គួរកុំផឹក។ | ជាប់សុក | ណាខ្មែរអើយ!!! |

ឌុម - នាគ្រី (កម្ពុជសុរិយា ១៩៤១)

## ក- សព្ទពន្យល់

និន្ទា= (ម. ថ. និន–ទា) ដំណើរគេតិះដៀល, ដំនៀល

ទុក្ខបច្ចុប្បន្ន= (ម. ថ. ទុក - ប័ច - ចុ: ប៊ន់) សេចក្តីព្រួយបារម្ភ, លំបាកជាពេលឥឡូវនេះ

ទុគ្គតិភព= (ម. ថ. ទុក - គ: តិភព់) កន្លែងកើតនៃសត្វដែលមានគតិអាក្រក់ គឺអបាយភូមិ ៗ

ងប់= ដ្រប់ដោក ; មុខរឹង ៗ

## ១- គំនិត

ស្រាធ្វើឲ្យយើងវង្វេងខកខួរក្បាល ភ្លេចស្គាល់អាក្រក់ល្អ មាន

ស្រាតខោដោះអាវដេកដោយផ្លូវជាដើម ; ភ្លេចបាបបុណ្យគុណទោស... ។ល។

មិនតែប៉ុណ្ណោះសុរានាំឲ្យ (សុរាបទកៈ) វិនាសទ្រព្យសម្បត្តិ, កេរ្តិ៍ឈ្មោះយសសក្តិ, កូនប្រពន្ធ, ទាំងនាំឲ្យមានពាក្យគរហានិន្ទាពីពាសកជន... ទាំងនាំឲ្យវិនាសទឹកដីថែមទៀត ។ សុភាទន្សាយបន្ថែមថា "ឆ្កួតមានបី"

« បៀស្រាស្រីតាំងបីនេះនាំឲ្យខូច នាំឲ្យខាតតាំងពីតូចលុះដល់ធំ
« លុះដល់ធនធានរលាយកាយក្រៀមក្រំ កាយក្រៀមក្រែប្រឹងទំ
« កែមិនបាន ។ តែមិនបាត់ចាត់ជាឆ្កួតហើយ វាឆ្កួតហួសលាត់
« សើយមិនដឹងប្រាណ មិនដឹងប្រាប់ថាម្តេចឲ្យស្តាប់បាន ឲ្យស្តាប់
« បើមិនដឹងដានត្រូវលះបង់ ។
« ត្រូវលះបែរបោលបៀស្រានឹងស្រី ស្រានឹងស្រូបទឹកដីត្រូវ
« លែងចង់ត្រូវលែងបេះលេងល្បែងដើរផ្លូវត្រង់ ដើរផ្លូវត្រូវលះ
« បង់ទើបចំរើន ។

"សុភាទន្សាយ"

## គ – សុភាសិត

« មើលមេរៀនទី ៦២ និង ៦៥ »

## ឃ- ពាក្យសួរ

អ្នកបានស្តាប់ឮ អ្នកផឹកស្រវឹង តែងពោលពាក្យដូចម្តេចខ្លះ ពេលជួបពួកម៉ាក? ដូចម្តេច បានជាថា អ្នកផឹកសម្លាប់ជាតិ? សាសនា? យោបល់យល់ឃើញរបស់អ្នក អំពីទោសនៃសុរា ។

---

# មេរៀនទី២៤

## ត្រូវស្នេហាជាតិ

បើបងប្អូនស្នេហាជាតិ ត្រូវយើងខ្មីឃ្មាតគ្រប់គ្នា
ជួយលើកដំកើងកម្ពុជរដ្ឋា ឲ្យបានថ្លៃថ្លាប្រសើរខ្ពស់ ។
ចូរយើងព្រួតដៃដំកើង ដាស់គ្នីគ្នាឡើងឲ្យស្របស្រុះ
ជួយរុញជួយច្រានឲ្យបានខ្ពស់ ឲ្យបានលូតលាស់ផុតទុក្ខភ័យ ។
មិនត្រូវយើងដេកមើលបំណាំ ប្រចាំក្នុងចិត្តមិនបេតី
គិតឲ្យតែរស់ខ្លួនឯងនៃ ធ្មេចភ្នែកមិនខ្ចីមើលជាតិខ្លួន ។

តរុណាបុត្រ

## ក- សព្ទពន្យល់

កម្ពុជរដ្ឋា=នគរកម្ពុជា , នគរខ្មែរដែលយាយតាទុកមកដោយឈាម ឆ្អឹង ។

ផុតទុក្ខភ័យ = ផុតអំពីទាសភាព;

មិនបេតី = ក្នុងទីនេះ មិនរវល់ដល់, មិនអើពើ ។

## ខ - គំនិត

បើយើងពេញទីជាអ្នកស្នេហាជាតិ ត្រូវធ្វើការឲ្យជាតិកុំមើលបំណាំគ្នា ។

## គ - សុភាសិត:

" ត្រូវព្យាយាមទ្រាំលំបាកយ៉ាកទល់ទុក្ខ ឲ្យតែបាន

" ជាតិលឿនទៅមុខបានក្សេមក្សាន្ត ជាតិសាសនា

" ទឹនមហាក្សត្រយើងថ្កើងថ្កាន ក៏ព្យាយាមឈ្មោះថាបានសម្រេច

" ផល ។

សុវណ្ណបុត្រ

## ឃ - ពាក្យសួរ

ធ្វើដូចម្តេចខ្លះ ដែលហៅថាស្រឡាញ់ជាតិ?

អ្នកយល់ដូចម្តេចខ្លះ តាមរឿងនេះ?

# មេរៀនទី ៧៥

## ឧបាយអ្នកស្រែម្នាក់

កាលនោះអ្នកស្រែម្នាក់ យល់ប្រត្យក្សថាអាត្មា
ជិតដល់មរណា អស់សង្ខារក្នុងពេលឆាប់ ។
កូនប្រុសគាត់មានបី គាត់ឃ្លាតខ្ចីហៅមកប្រាប់
ថាបូរអ្នកប្រុងស្តាប់ ឪពុកប្រាប់ការណ៍ឧត្តម ។
ឱ! កូនមាសឪពុក! ឪផ្តាំផ្តុកឲ្យកូនចាំ
ស្រឡាញ់គ្នាបូរកុំ ឈ្លោះគំនុំគុំគួនគ្នា ។
អំណើះពីឪទៅ កូនប្រុសនៅត្រូវស្នេហា
កុំឲ្យបែកបែះឆា ទាស់ទែងគ្នាណាឧត្តម ។
ប្រាក់ណែនមួយក្រឡ ឪអង្វរឲ្យកូនចាំ
ក្នុងស្រែស្វែងរកកំ- ណប់ប្រាក់ដែលឪកប់ទុក ។
លុះគាត់ថ្លែងចរចា ប្រាប់បុត្រាអស់ទំនុក
ទើបបុរសឪពុក ក្សីណក្ស័យជន្មក្នុងពេលនោះ ។
ឯកូនទាំងបីនាក់ ភ្ជួររកប្រាក់ពុំឃើញសោះ
គំនិតទាល់ទាំងអស់ មិនឃើញព្រោះឧបាយកល ។
លុះក្រៀងបន្តុមក ស្រែដោរដោកសត្វឥតសល់

នាំគ្នាគិតខ្វាយខ្វល់ សាបហើយសួនកុំឲ្យខាន ។
លុះដល់ខែមិគសិរ ស្រូវនោះផ្លែទុំសន្ធាត
នាំគ្នាច្រូតខ្វល់ឃ្នាត ច្រូតហោកបែនដាក់ដង្រែន ។
លែតូដបំអែតប្រាណ សល់ប៉ុន្មានយកទៅលក់
បានប្រាក់ល្បីកូនស្រុក គទៅមុខចំលើសដើម ។

(ស្រង់ពីទស្សនាវដ្ដីសិក្សាឆ្នាំ១៩៥២)

## ក– សព្ទពន្យល់

ប្រត្យក្ស= (ម. ថ. –ត្យ័ក) ឬ ប្រចក្ស = ដែលជាក់ច្បាកដ, ច្បាស់, មែន ។

មរណា= (ម. ថ. ម: រ: នា") សេចក្ដីស្លាប់

ការណ៍= ហេតុ

ឧត្ដម = ប្រសើរ

បរបា= និយាយ

ជិន្ន= (ម. ថ. ជន្នៈ ឬជន់) ជីវិត

ឧបាយកល= ទបាយយ៉ាងល្អិត, ល្បិច ។

## ខ–គំនិត

អ្នកស្រែម្នាក់នេះ ពិតតែក្រទ្រព្យសម្បត្តិ តែគំនិតប្កុឧបាយរបស់គាត់មិនក្រ ( ខ្វះ ) ទេ គាត់ខំឆ្លៀតឱកាសទីបំផុត នឹងបញ្ឆោតកូនគាត់ ដោយឧបាយឲ្យខំកាយដីញីកក់ធ្វើស្រែបានស្រូវច្រើន ។

## គ – ពាក្យចាស់បូរាណ

« ប្ដូរយើងកោតខ្លាច    កុំធ្វើកោងកាច    នឹងអ្នករកស៊ី
« ធ្វើស្រែបំការ    កាយព្រះធរណី    តាមពាក្យប្រាំពីរ
« ឃ្លានេះទុកមក ។ « កូនអើយរកស៊ី    កាយព្រះធរណី
« ប្រពៃកន្លង    កុំបាខ្ពើមខ្អើម    ដាំដើមឈើផង
» បរិសុទ្ធិឥតហ្មង    ចិញ្ចឹមជីវិត ,, ។

## សុភាសិតបិៈ « ការងារជាឃ្លាំងប្រាក់ »

« ធ្វើការបានប្រាក់    ធ្វើការបានស័ក្ដិ    ធ្វើការបានយស
« ធ្វើការបានទ្រព្យ    បានវិជ្ជាស្មោះ    ចំរើនឥតថ្កស់
« ដោយសារការងារ »

ហ៉យ-ប៊ុក ( សុភាសិតបារាំង )

## ឃ – ពាក្យសួរ:

អ្នកស្រែនិយាយប្រដាក់ប្រទុក្ខកូនគាត់ម៉េចខ្លះ ពេលដែលគិតជិតដកដង្ហើមទីបំផុត ( ស្លាប់ )? អ្នកយល់ថាដូចម្ដេចខ្លះ ក្នុងមេរៀននេះ?

# មេរៀនទី៣៦

## ខ្មែរអង្គរ

ស៊ូស្លាប់ព្រោះជាតិ ទើបប្រសើរគាប់ រស់នៅមានភ័ព្វ
ត្រូវហ៊ានតក់ ឥតស្តាយសង្ខារ ទើបពេញជាខ្មែរ
ពួកយើងរាប់លាន បើគេបំពាន ត្រូវហ៊ានតុះតារ
កុំស្តាយជន្មា ការពារឯករាជ្យ ។
កុំជឿពាក្យគេ បែរគ្នើជាខ្មាំង ប្រកួតប្រចាំង
នឹងខ្មែរគ្នាឯង ។

បុរាណលោកផ្តាំ បួនអ្នកបងចាំ កុំភ្លេចសោះឡើយ
ខ្ញុំគេពិបាក តោកយ៉ាកឥតស្បើយ ហេតុនេះបួនអ្នក
កុំភ្លើកភ្លើយ កៀកកគ្នាហើយ ក្រោកឈរស្មើគ្នា ។
ទ្រទ្រង់មហាក្សត្រ នឹងព្រះសាសនា តាមពង្សាវតារ
ដែលខ្មែរជួនតា យើងបន្តុកមក ។
វេទន៍ខ្ញុំគេ ពិបាករិះរេ ដោយពាក្យសំដី
បើពោលឲ្យខ្វី គេបិទគេខ្ទប់ បក្សសោតា
កាយាមហិមា ត្រូវគេឃាំងដៃ បើចង់កែប្រែ
ត្រូវមានសារីរុធ ។

ទើបបានគត់មត់ ក្នុងការបរបា សាសន៍ផ្លូវច្បាប់
ឲ្យល្បីបំណាច់ ខ្លះតបពលកាយ ទើបមានអ្នកប្រាជ្ញ
ក្នុងទីជិតឆ្ងាយ ពប់មុខយើងអើយ ។

(ព៉ិន - ស៊ីកែវ)

## ក- សព្ទពន្យល់

ភ័ព្វ= (ម. ថ. គាប់) សេចក្ដីចំរើន, ដំណើរកើត, ព្រេងសំណាង ។

ខ្មាំង= សត្រូវ

គេបិទគេខ្ទប់បក្ខុសោតា= គេបិទភ្នែកយើងមិនឲ្យឃើញនាយអាយ ទឹងបុកត្រចៀកយើងមិនឲ្យឮសំឡេងជិតឆ្ងាយ

សិរីរុង= សេចក្ដីចំរើនបរិបូណ៌ដោយទឹកចិត្ត គ្រឿងស្ដ្រារុង

បរបា= និយាយ

## ១- គំនិត

គ្មានឧបសគ្គអ្វីដែលគួរឲ្យពិបាកនោះទេ បើជាតិយើងមានឆន្ទៈស្របគ្នា រួមគ្នាបងជាប់ ... ធ្វើការស្ទួយមាតុប្រទេសដោយស្វកាន់ទាន់កាលៈទេសៈ ។ ការលើកដំកើងមាតុប្រទេស ដោយពលរដ្ឋម្នាក់ៗ មិនគិតផលប្រយោជន៍ផ្ទាល់ខ្លួននេះ ជាប្រធានធ្វើឲ្យប្រទេសរុងរឿងឆាប់

ពាន់ការប្រទេសមុនៗ មិនខាន ៗ

## គ – សុភាសិត

" ស៊ូស្លាប់ព្រោះជាតិ គួរខំខ្មីឃ្មាត ឲ្យជាប់និស្ស័យ
" កើតជាកូនប្រុស គួរកុំអាល័យ រូបកាយក្សិណក្ស័យ
" កេរ្តិ៍ឈ្មោះគង់នៅ ,,

ស៊ិន - ស៊ីវ " ភាសិតសង្គ្រោះ ,,

## ឃ – ពាក្យសួរ:

លោកថា " ស្លាប់ព្រោះជាតិទើបប្រសើរគាប់ " នោះ បានសេចក្ដីថ្លៃថ្លាយដូចម្ដេចខ្លះ ? ក្នុងមេរៀននេះ តើចិត្តអ្នកនិពន្ធសំដៅទៅកាន់ផ្លូវណា ?

---

## មេរៀនទី២២

### សេចក្ដីរំលឹក

នគរយើងពីដើមធំទូលាយ ដោយចិត្តភាយបែកសាមគ្គី
អភ័ព្វបង់ខាតរាជធានី សត្រូវពាធីបៀតបៀនបាន ៗ
ប្រាសចាកថ្ងៃថ្នូរពីកាលណោះ ស្ត្រីប្រុសក្មេងចាស់ទាំងប៉ុន្មាន
អាប់ឱនកើតទុក្ខសឹងគ្រប់ប្រាណ ងើបមុខមិនបានយូរឆ្នាំហើយ ៗ

ខ្មែរអើយប្អូនអ្នកភ្ញាក់កំណើត ខំធ្វើឲ្យកើតគតិកាញ់គ្នារ
កុំបែកគំនិតខុសទទេ ទំនេរវះគិតគ្រប់ៗប្រាណ ។
កម្ពុជាតូចពិតដូចពេជ្រថ្លា តាមពង្សាវតារពីបុរាណ
សឹងមានកេរ្តិ៍ឈ្មោះយ៉ាងបំណាន បានសាងទុកមករបស់ខ្មែរ ។
ដូច្នេះកុំបែរទៅណាៈសោះ តាំងចិត្តឲ្យស្មោះមិនត្រូវប្រែ
ផ្ទងផ្តើមរៀនខ្លួនរាល់ថ្ងៃខែ ពលរដ្ឋមុខតែមានអំណាច ។

"ខ្មែរកំសត់"

## ក– សព្ទពន្យល់

បិត្តភយ = ធ្វេសប្រហែស, ភ្លេចខ្លួន
សាមគ្គី = សេចក្តីមូលមិត្តមេត្រីគ្នា, ព្រមព្រៀងគ្នា
រាជធានី = ទីក្រុងធំ, ទីប្រជុំធំ, កន្លែងវិសេស
ភ្ញាក់កំណើត = ស្ទុះបើកភ្នែកធំឡើងមើលនាយអាយតើម៉េច?
ពលរដ្ឋ = រាស្ត្រទូទៅ

## ១– គំនិត

ជាតិខ្មែរដែលថយអំណាច ធ្លាក់ខ្លួនជាទាសភាព ព្រោះតែខ្វះធម៌សាមគ្គី; អសាមគ្គី ជាប្រធាននៃសេចក្តីវិនាស !

## គ- ពាក្យសួរ

" ត្រូវលះបង់ប្រយោជន៍ខ្លួនទាំងគ្រួសារ ជួយប្រយោជន៍ជាតិ-
សាសនាទាំងមហាក្សត្រ លះជីវិតគិតការបំរើរដ្ឋ
នេះទើបខ្ចាត់ចាកទីទាបភាពខ្ញុំគេ !

" សុវណ្ណបុត្រ "

## ឃ- ពាក្យសួរ

ព្រោះហេតុអ្វីបានជាខ្មែរធ្លាប់ចុះចាញ់សព្វថ្ងៃនេះ ? ចុះបើចង់ឲ្យជាតិបានចម្រើនរុងរឿងដូចដើម តើពលរដ្ឋម្នាក់ ៗ ត្រូវធ្វើអ្វីខ្លះ ?

---

## មេរៀនទី ៣៨

**ជីវៈ ផ្តុំគ្នា**

អង្គមនុស្សជាសត្វលោកលូតលាស់បានបញ្ញាប្រាណ ស្ថានចិត្តប្រែប្រួមតាំងពី
ដោយការរស់ព្រោះជុំគ្នាជាប្រក្រតី ទាំងប្រុសស្រីក្តីសព្វកាលក៏ដូច្នេះ ៗ
រស់តែឯងតែងតែព្រួយព្រោះត្រូវការ ទាំងអាហារសារវិជ្ជាចិត្តបំណោះ
ពល់រូបាការត្រង់ហ្នឹងនេះត្រូវចេះយល់ប៉ុណ្ណោះចេះប៉ុណ្ណឹងទាំងហៅមនុស្ស ៗ

ជាតិជាមនុស្សផុះផាលបានប្រាណពឹងគ្នា ខ្វះនានាអ្នកនៅក្រុងក្រៅត្រូវ

លុះ

ប្រាស្រ័យគ្នាជាញឹកញយដោយស្ម័គ្រស្មោះ ធ្វើដូច្នោះរូបរស់វេងសុខសាន្ត

រស់ផ្តុំគ្នាជាការគួរគិតរាល់ថ្ងៃ ជីវៈថ្ងៃថ្នារុងរឿងរិះរកស្ពាន

គួរសេពគប់គប្បីបៀសបេញប្ហខាន រើសមជ្ឈដ្ឋានបានទើបពឹងពាក់

អាត្មា ។

ខបញ្ញាការត្រង់ហ្នឹងនេះសូមស្តី យ៉ាងគប្បីបើជនជាតិបង់ប្រាជ្ញា

ត្រូវសេពគប់ស៊ីបទឹងប្រាជ្ញព្រមទាំងការ ដែលលោកចារស្នាដៃដែល

លោកធ្វើ ។

បណ្ណាល័យថ្ងៃលើសលប់កតស្ពានផង ជាបំណាច់បង់កុលបុត្រសុទ្ធប្រសើរ

ភ្ជាប់ទឹងប្រាជ្ញព្រោះទីនោះស្មោះគ្រាន់បើ នាំជនដើរដោយគតិទូទៅល្អ ។

មានត...

## ក- សព្ទពន្យល់

ជីវៈ= ( ម.ថ.ជី-វ៉ៈ ) ការរស់នៅ

មជ្ឈដ្ឋាន= (ម៉.ថ.មុ៉ច-ឈ័ត-ឋាន ) កន្លែងកណ្តាល

## ១- គំនិត

មនុស្សយើងរាល់រូបក្នុងលោកនេះ ដែលទឹងចុំចើងល្បួតលាស់ទាន់

សម័យបាន, ឋិតថេរបាន អាស្រ័យតែពីបញ្ញាឆ្លៀវឆ្លាតស្គាល់ចិត្តគ្នា ក្នុងសង្គមរហូតដល់ទូទៅទាំងពិភពលោក ; ពោលគឺត្រូវមានសាមគ្គីចងបាច់គ្នារវាងជាតិនិងជាតិ... ។

## គ- សុភាសិត

“ ឱ ! បុរសកំជិល ! ចូរអ្នកមើលសត្វឃ្មុំនិងស្រមោចតើ
“ វាធ្វើការសព្វ ៗ ថ្ងៃដូចម្ដេចខ្លះ ? ”

## ឃ- ពាក្យសួរ

អាស្រ័យអ្វីជាបច្ច័យ ទើបមនុស្សយើងលូតលាស់បាន ? ដូចម្ដេចបានជាលោកថា ការប្រាស្រ័យគ្នាជាញឹកញយនាំឲ្យបានសេចក្ដីសុខ ? អ្នកយល់ម៉េចខ្លះ ?

---

## មេរៀនទី ២៩

### ជីវៈជុំគ្នា (តបប់)

វណ្ណមណ្ឌលដែលប្រជុំជួបមិត្តភាព យ៉ាងសុភាពគប់មេត្រីក្ដីស្មោះសរ
ជជែកគ្នាជាបទបាតបានសាទរ បញ្ចេញវវង់បញ្ញា សារប្រយោជន៍ ។
គេប្រឹក្សាការគេពើបពះគំនិត ល្អពិតៗចិត្តសោមនស្សស្រស់មិនខ្វាច
គេត្រងរើសសន្ទនាជាប្រយោជន៍ បើយ៉ាងហោចហើយមួយពេលតុំ

សោះសូន្យ ៗ

វណ្ណមណ្ឌលដែលប្រជុំក្រុមកីឡា   គេឧស្សាហ៍សាងសមគ្គាជាបងប្អូន
នាំគ្នាហាត់អត្តពលកម្មការនេះជូន   ធ្វើឲ្យពូនពេញសាច់ដុំធំធាត់ល្អ ៗ
មានកម្លាំងខ្លាំងទីងប្រព្រឹត្តការអ្វី   ធ្វើករណីយនោះទីងកើតការមិនក្រ
គាំពារខ្លួនផ្លូនជាមានមហាភ័យមក   បើទីងរក៏យក៏អាសាការគេកើត ៗ
វណ្ណមណ្ឌលដែលប្រជុំបំពោះបុណ្យ   ចិត្តមិនដុនជាបទីងទន់ភ្លន់ល្អឆើត
គេខំថ្នៃខគុណធម៌ល្អកំណើត   សន្តានកើតកេរ្តិ៍ស្មុកមង្គលថ្លៃ ៗ
ជីវភាពផងក្នុងទីតាំងឡាយណា   មានសាភការណ៍ពីព្រោះមនុស្សដម្លៃ ៗ
ប្រជុំគ្នាជាស្និទ្ធស្នាលស្មើអស់ន័យ   ហៅប្រពៃពិតមែនជីវៈភាពនោះ ៗ

ពន្ធកពន្ធ

## ក– សព្ទពន្យល់ៈ

វណ្ណមណ្ឌល= ម. ច. វ័ន-ម៉ន-ឌល់) ជុំវិញផែនដី ! ទីនេះ សហភាព ឬ សហប្រជាជាតិក្នុងលោក ៗ

សន្ទនា= (ម. ច. សន់-ទៈនា) និយាយគ្នា,

កីឡា= ល្បែង

អត្តពលកម្ម= (ម. ច. អ័ត-តៈ-ពល់លៈកាំ) ការហាត់ខ្លួនប្រាណ

មហាភ័យ = ភ័យដ៏ធំ

សុភមង្គល = ( ម. ថ. សុំ - ភៈ - ម៉ុង - គល់ ) សេចក្ដីសុខ - ចំរើន

ការណ៍ = ហេតុ

## ១- គំនិត

" មើលមេរៀនមុន.. "

## គ- សុភាសិត

" សាមគ្គី ជាកំឡាំង "

" កំឡាំងធំផុត សាមគ្គីមោះមុត ព្រមព្រៀងមូលមួយ "
" កាយវាចាចិត្ត ស្រុះស្រួលខំជួយ ចុកបែវរង្ឈួយ "
" សួយជាតិដល់ត្រើយ " ។

ហ៊យ - ប៊ុក ( សុភាសិតបារាំង

## ឃ- ពាក្យសួរ

តើអ្នកយល់ដូចម្ដេចខ្លះក្នុងមេរៀននេះ ? តើអ្នកនិពន្ធចង់និយាយ

ទៅផ្លូវណាខ្លះ ?

# មេរៀនទី ៨០

## គោលបំណងខ្មែរ

ខ្មែរយើងធ្លាប់ថ្កើងពីបុរាណ ធ្លាប់អាចក្លាហានពូកែពិត
ធ្លាប់ឈ្នះអំណាចបច្ចាមិត្រ ប្រទេសឆ្ងាយជិតសឹងខ្លបខ្លាច ។
កាលសម័យនគរវត្ត តែខ្មែរបានភ្លាត់ធ្លាក់អំណាច
ទន់ខ្សោយថយចុះធុះដាប់ដាច តែខ្មែរនៅអាចទប់ខ្លួនបាន ។
នៅជាតិសាសនាព្រះមហាក្សត្រ នៅមានប្រដ្ឋប្រទេសស្ថាន
ទោះបីទន់ខ្សោយទៅប៉ុន្មាន គង់ទប់ខ្លួនបាននៅរៀងរាប ។
រហូតមកដល់យុគសព្វថ្ងៃ ជាកាលសម័យត្រូវមានលាភ
មនុស្សលោកត្រូវមានសេរីភាព ស្មើមុខរៀងរាបដូច ៗ គ្នា ។
ពេលនេះត្រូវខ្មែរប្រែគំនិត ខំប្រឹងរិះគិតកុំរួញរា
ខំរៀនខំរកគ្រប់វេលា ដើម្បីពុះពារធ្ងន់គ្រោះថ្នាក់ ។
បញ្ហាស្មុគស្មាញច្រើនអន្លើ ដែលយើងត្រូវធ្វើដោយចិត្តស្មគ្រ
ដោះស្រាយឲ្យបានគ្រប់ ៗ ថ្នាក់ ឲ្យបានដល់ឡាក់គោលប្រាថ្នា ។

(ខ្មែរក្រោក ១៩៥២)

## ក- សព្ទពន្យល់

បញ្ញាមិត្ត= ម.ជ. ជ៉ាប់–ចាមិត្រ សត្រូវ

ប្ររដ្ឋ= (ប្រៈ–រ័ត) រដ្ឋដទៃ; នគរដទៃ

សេរីភាព= មានភាពស្មើ ៗ គ្នា, ឯករាជ្យ

## ខ- គំនិត

ខ្មែរយើងពីដើម ជាជាតិមួយមានល្បីឈ្មោះជាងគេក្នុងការស៊ូទ្រាំ ៗ ដូច្នេះ, យើងជាកូនចៅត្រូវយកតំរាប់តាមវីរបុរសយើងជាន់នោះឲ្យបាន ៗ

## គ- សុភាសិត

ខ្មែរ គឺជាជនជាតិមួយក្លាហាន ហើយប្រកបដោយឧត្តមគតិគ្រប់គ្នាទាំងអស់ ៗ

"គតិសាស្ត្រ"

## ឃ- ពាក្យសួរ

តើអ្នកយល់ដូចម្ដេចខ្លះ ក្នុងមេរៀននេះ ៗ

# មេរៀនទី ៨១

## ការសិក្សា

ជាតិអើយគតិលោកសព្វថ្ងៃ កុំគិតសង្ស័យត្រូវស្អាត
រៀនគ្រប់បំណេះឲ្យដល់ខ្នាត កុំឲ្យប្រមាទការសិក្សា ។
មានកូនអាយុ ៦ ឆ្នាំ កុំចាំមេឃុំដាស់តឿនថា
នាំកូនចូលទៅកាន់សាលា រាជការបម្រើកន្ទួងស្រាប់ ។
មានតុកៅអីឲ្យអង្គុយ ក្បាលមីរង្គុយ គ្មានស្អុះស្អាប់
បង្រៀនទាំងផែនទីទាំងសាវតារ ដល់ពួកកុមារដែលនៅល្ងង់ ។
ការរៀនមានព្រះរាជប្រកាស ព្រះករុណាត្រាស់ឲ្យបម្រុង
ដល់ឆ្នាំចូលរៀនកុំបង្អង់ តែទុកការង់ត្រូវមានទោស ។
ជាបទលហុដល់មេបា ដែលស្នេហាកូនហើយសន្ដោស
សណ្ដាប់ខុសច្បាប់ត្រូវមានទោស កុំសន្ដោសកូនហួសមាត្រា ។
ហ្នឹងហើយមេបានាំឲ្យខូច ដល់ត្រកូលពូជពង្សវង្សា
ដែលកូនកើតមកក្នុងលោកា ត្រូវមេបានាំរៀនបំណេះ ។
បើមិនចង់ធ្វើជាមន្ត្រី ចង់រកស៊ីអ្វីត្រូវតែចេះ
ដឹងកលស្គាល់កិច្ចល្បិចជម្រះ រកស៊ីត្រូវចេះក្បួនការងារ ។

មុក - ចួន (សុភាសិតោវាទ)

## ក– សព្ទពន្យល់

ប្រមាទ= (ម.ថ.-មា៉ត) ការភ្លេចស្មារតី, ធ្វេសស្មារតី សេចក្ដីប្រហែស ៗ

## ខ– គំនិត

អារ្យប្រទេសទាំងឡាយដែលនឹងរុងរឿងស្ថាពរបាន កំព្រោះតែពីការសិក្សាជាបឋម, ក្មេង ៗ ដែលមានវ័យល្មមសូត្ររៀនគេឲ្យបញ្ជូលសាលាគ្មានសល់ម្នាក់ព្រោះការសិក្សាជាកិច្ចប្ដេជ្ញារបស់ជាតិអ្នកមានថ្លៃថ្នូរ ៗ

## គ– សុភាសិត

១ – “ ម្ដាយឪពុកទុកកូនមិនឲ្យរៀន បំណះរបៀនការនានា
“ មាតានោះទុកជាវេរា បិតាទុកជាសត្រូវធំ ៗ
“ លុះកូនពេញពាលពត់មិនឡើង មិនបានចំរើនក្នុងជំនុំ
“ ប្រៀបដូចកុកក្រោងចូលស្មាគម កណ្ដាលប្រជុំរាជសីហា ៗ

ចាប - ពិន

២ – “ រីការសិក្សា បំណះវិជ្ជា ផ្លូវធម៌ផ្លូវលោក
“ បីដូចកូនសោ ចាក់ទ្វារឃ្លាំងភោគ សម្បត្តិភោគ
“ កន្ទនាលោកិយ ”

ភ៉ុយ - ប៊ុក

## ឃ- ពាក្យសួរ

ដូចម្តេចបានជាក្មេងមានអាយុ ៦ ឆ្នាំ ត្រូវបញ្ជូនទៅសាលា? មានទោសត្រឹមណា ម្តាយឪពុកដែលមានកូនគិតតែឱបក្រសោបកូន ឲ្យនៅផ្ទះជួយធ្វើការជួយដៃជើង ? តើទៅជាអ្វីទៅ បើជាតិនីមួយមិនប្រឹងការសិក្សាឲ្យមាំមួន ? យោបល់ ៗ

---

## មេរៀនទី ៨២

### កិរិយាមិនគួរ

កូនអើយធម្មតា
ពាលាឈ្លានពាន
ពុំសុខក្សេមក្សាន្ត
ដល់អ្នកនោះណា ៗ
គេចាប់របស់
ខូចទាំងទ្រព្យដើម
ព្រោះតែអាត្មា
ហេតុកម្មខ្លួនឯង
អំពើពុំគាប់

កាន់ចិត្តឫស្យា
ច្រើនតែកើតទុក្ខ
ភិតភ័យច្រើនមាន
លុះតៀរមកដល់
ចង់វាយផ្ទួនា
កូនចៅកិរិយា
លោកចង់បានចាប់ ៗ
ចិត្តកាចពុំលែង
គេចាប់យកទៅ

ធ្វើបាបស្ទើរស្លាប់ ដល់ដាក់គុកខ្នាប់
ទ្រព្យសោតអន្តរាយ ។

(ខ្មែរក្រោកឆ្នាំ ១៩៥២)

## ក- សព្ទពន្យល់

ចិត្តឫស្យា= ចិត្តកាចឃោរឃៅ, ចិត្តអាក្រក់លាមក

ពាលោឬពាល= ជនកាចសាហាវ, ព្រើលព្រហើនកោងកាច ដូចកូនក្មេង ។

ពៀរ= បំណងចិត្តក្រោធ ដែលចងដោយព្យាបាទ បំរុងនឹងសងសឹកវិញ ; បំណងចិត្តជាសត្រូវ ។

ផ្ដិន្ទា= (ម. ថ. ផ្ដន់ទា) ផ្ដាលផ្ដាញ់, ធ្វើទោសផ្ដាល, បង់ឲ្យវិនាស

កម្ម= (ម. ថ. កាំ) អំពើដែលធ្វើ, ទោះបីល្អឬអាក្រក់ហៅថាកម្ម ។

ទ្រព្យសោតអន្តរាយ= ទ្រព្យរលាយអស់រលោះឯងខ្ចាត់ខ្ចាយដូចទឹកហូរធ្លាក់ចុះពីកំពូលភ្នំ ។

## ១- គំនិត

យើងមិនអាចស្គាល់ចិត្តថ្លើមមនុស្សក្នុងលោកនេះទេ, តែក្នុងលោកនេះ មានមនុស្សពាលច្រើនគណនារាប់មិនអស់ ។ ពាលប្រព្រឹត្ត

អំពើអយុត្តិធម៌ លោកទ្រព្យសម្បត្តិគេបង់បានធ្វើមានតែឯងដាច់ ក្មេច គេពល់គ្នាទៀតហត់.... ឯកម្មដែលខ្លួនធ្វើនោះ មុខជាឲ្យផលឃើញទាន់ភ្នែកមិនខាន (ទិដ្ឋធម្ម) ។

" បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សពាលតែងសំគាល់នូវបាប
" ថាដូចជាទឹកឃ្មុំត្រឹមនោះ លុះតែកាលណាបាបឲ្យផល មនុស្ស
" ពាលទើបប្រទះនូវសេចក្ដីទុក្ខក្នុងកាលនោះ " ។

ព្រះឧត្តមមុនី អ៊ុម-ស៊ូ (១០០ គាថា)

## គ– សុភាសិត

១– « ទ្រព្យបានដោយទុច្ចរិត មិនដែលចំរើនសោះឡើយ »
« ទ្រព្យលួចប្លន់បាន ធ្វើដើមធនធាន រកស៊ីកែខៃ
« មិនដែលចំរើន បាត់សូន្យ មុខជាហិនហៃ
« វិនាសហិនហោច " ។

(លោកកើយ-ប៊ុក (សុភាសិតបារាំង)

២– « បុរីណាដែលប្រកបដោយមនុស្សពាល ទោះធំ
« ស្ទើនឹងមេឃក៏ដោយ, ទោះសម្បូណ៌ឬចំរើនដោយ
« ប្រការណាក៏ដោយ, បុរីនោះនឹងរលាយពុំខានឡើយ » ។

៣– « តែអ្នកប្រព្រឹត្តអំពើពាលទៅថ្ងៃមុខខ្លួនអ្នក, ញាតិអ្នក

“ទីង៍វេទនា ហើយទីង៍សោកាព, ខាតឯករាជ្យ, ខាតទំហំ

“អាណាចក្រជាមិនខាន” ។

ខេមរសន្តិភាពល.ស. (គតិសាស្ត្រ)

## ឃ- ពាក្យសួរ

ដូចម្តេចបានជាអ្នកប្រព្រឹត្តអំពើពាលចិត្តបុស្សា ច្រើនតែមានទុក្ខ? ទុក្ខដូចម្តេចខ្លះ ចូរអ្នកឲ្យយោបល់ ។

---

# មេរៀនទី ៨៣

## ជាតិ

ជាតិកម្ពុជា ធ្លាប់ល្បីនាមា អំពីព្រេងនាយ
សម័យអង្គរ ល្បីខ្ទរសុសសាយ ជាតិយើងសប្បាយ
ច្រើនបុណ្យច្រើនស័ក្តិ ។

ជាតិកម្ពុជា ធ្លាប់ល្បីនាមា រួមចិត្តស្មោះស្ម័គ្រ
កសាងប្រទេស ឥតធ្វេសគ្មានអាក់ ជាតិខ្មែរបែរកក្រ
ទាន់កាលសម័យ ។

ជាតិកម្ពុជា ធ្លាប់ល្បីនាមា ដោយសារស្នាដៃ
កសាងប្រាសាទ ស្អាងស្អាតថ្លាថ្លៃ ធ្លាក់ចម្បរណៃ

ល្អឯកក្នុងលោក ។

ជាតិខ្មែរតទ្រូវ ត្រូវដើរតាមផ្លូវ គន្លងជ័យជោគ
ព្យាយាមកសាង យ៉ាងសម័យគោក - ដូចខ្មែរសាងលោក
ទុកកេរ្តិ៍កូនចៅ ។

ឱបងប្អូនខ្មែរ គួរគិតកែប្រែ គំនិតឲ្យជ្រៅ
ព្រួតដៃបង្ហាប់ ញាតិសាច់ពង្សផៅ រួមជនក្នុងក្រៅ
កសាងជាតិយើង ។

បងប្អូនរួមជាតិ ត្រូវខំខ្មីឃ្មាត ជួយជាតិឲ្យចំរើន
ឲ្យខ្មែរលែងក្រ កាន់ថ្នាក់ខ្ពស់ឡើង រុងរឿងជាតិយើង
ជយោជាតិខ្មែរ ។

ស្រង់ពីសៀវភៅត្រែសារណដ្ឋានរបស់ប្រទេសជាតិ ឬស.ក. “ជាតិ-សាសនា-មហាក្សត្រ របស់លោក (ញ៉ុក-ថែម)

## ក- សព្ទពន្យល់

ព្រេងនាយ= ពីកាលបុរាណនាយ, ដែលមានក្នុងកាលពីដើម, ដែលជាយូរអង្វែងហើយ ។

សម័យអង្គរ= សម័យ ឬជាន់ ឬជំនាន់ខ្មែរឯករាជ្យ, ឬកាលសម័យព្រះបាទជ័យវរ្ម័នទី ៧

ល្បីខ្ចរសុសសាយ = ខ្មែរពីដើមជាជាតិធ្លាប់មានល្បីកេរ្តិ៍ឈ្មោះ ជាជាតិក្លាហានការពារប្រទេសជាតិ ឲ្យបានគង់វង្ស . ហេតុដល់មានល្បីកិត្តិសព្ទឮទៅទាំងពិភពលោក ជាតិណា ៗក៏កោតស្ញើចនឹងស្នាដៃខ្មែរជាន់នោះដែរ ។

ស្មោះស្ម័គ្រ = សុចរិតនឹងការពារមាតុប្រទេស ។

ឥតធ្វេស = ក្នុងទីនេះ គឺថាមិនភ្លេចខ្លួន គឺថាមិនភ្លេចករណីយកិច្ចរបស់ខ្លួន ។

ភក្ត្រ ឬ ភ័ក្ត្រ = (ម. ថ. ភាក់) មុខ

បរ៌ណៃ = (ម. ថ. ប-រៈណៃ) កេរប្តូច្បន

ល្អឯក = ល្អលេខមួយ ; អំពីការកសាងប្រាសាទ ដែលយើងឃើញនៅមានបាក់បែកដល់សព្វថ្ងៃ ៗ ខ្មែរពីដើមមិនល្មមទេ គឺខ្មែរឯកកពដ្យ!

គន្លងជ័យជោគ = គឺខ្មែរពីដើមធ្លាប់ឈ្នះគេ - ឯកកពដ្យ!

សម័យគោកធ្លក = កាលខ្មែរនៅមានបុណ្យអំណាច អាណាខេត្រខ្មែរធំទូលាយណាស់ (បើកប្រវត្តិសាស្ត្រ ជំនាន់នោះមើលតើខ្មែរម៉េចខ្លះ គង់ដឹងបាន)

## ខ - គំនិត

ជាតិខ្មែរជាជាតិមួយធ្លាប់មានសេចក្ដីក្លាហានអង់អាច មានកិត្តិសព្ទល្បីទូទៅទាំងពិភពលោក ដោយការកសាងស្ពានអង្គរវត្តនឹងសាមគ្គីធម៌រវាងជាតិនឹងជាតិ ។

ពេលនេះ, ខ្មែរយើងអាប់ឱន ព្រោះតែខ្មែរយើងច្រើនគិតតែប្រយោជន៍ផ្ទាល់ខ្លួន ភ្លេចនឹកដល់ករណីយកិច្ចដែលត្រូវបំពេញទៅអនាគត ។

## គ - ពាក្យចាស់

“បើមិនបានដូចមុនទេ ត្រូវរក្សាមុនឲ្យស្ថិតនៅល្អហើយ” ។

## ឃ - ពាក្យសួរ

គេដឹងដោយអ្វីខ្លះ ថាខ្មែរសម័យដើមជាជាតិបរិបូណ៌ដោយភោគ-សម្បត្តិ, ក្លាហាន, សាមគ្គី? សេចក្ដីសាមគ្គីរវាងជាតិនិងជាតិបានផលដូចម្ដេចខ្លះ? ចូរអ្នកអធិប្បាយ តាមសេចក្ដីដឹង, ឮ, ឃើញអំពីកិត្តិសព្ទខ្មែរសព្វថ្ងៃ នឹងខ្មែរពីដើមសម័យអង្គរ ?

# មេរៀនទី ៨៤

## អំពីសាសនា

### ទី ២ សូមថ្លៃសាសនា

ជាទីពឹងផ្អែកដ៏ថ្លៃថ្លា មនុស្សគ្រប់លោកាធ្លាប់រាប់អាន ។
ទោះស្រុកតូចធំគ្រប់ភាសា តែងយកសាសនាជាប្រមាណ
សម្រាប់ជាតិគេពីបុរាណ កាន់តាមលំអានគ្រប់អាត្មា ។
ដូចខេមរជនយើងនេះឯង សុទ្ធតែសំដែងកាយវាចា
នឹងចិត្តគួបកាន់ពុទ្ធសាសនា រក្សាអស់ជាងពីរពាន់ឆ្នាំ ។
សាសនា ប្រែថាពាក្យទូន្មាន ច្បាប់ធម៌ដោយយានប្តូបណ្តាំ
ពុទ្ធៈ ប្រែសព្វតាមចំណាំ ថាលោកអ្នកចាំចេះលើសលុប ។
រួមពាក្យពុទ្ធៈនឹងសាសនា ប្រែថាវាចាប្រដៅគ្រប់
របស់ព្រះពុទ្ធម្ចាស់ត្រៃភព ជាទីគោរពពុទ្ធបរិស័ទ ។

ឃុន ឧត្តមប្រីជា ចាប - ពិន (ច្បាប់ប្រដៅកូនចៅខ្មែរ)

## ក- សព្ទពន្យល់

ត្រៃភព = ត្រៃ=៣, ភពៈ=ទីកើត; ត្រៃភពបានដល់ភពទាំង ៣- កាមភព, រូបភពនឹងអរូបភព ។

ពុទ្ធបរិស័ទ = (ម. ថ. ពុទ្ធ-ធ:-ប-រិស័ត) បរិស័ទនៃព្រះពុទ្ធ អ្នកកាន់ពុទ្ធសាសនា ។

## ខ – គំនិត

ដើម្បីចង់បានសេចក្ដីសុខ - បំរើនសិរីសួស្ដីជ័យមង្គលមនុស្សគ្រប់សាសន៍ក្នុងលោកត្រូវការរាប់អាន កាន់សាសនា, ព្រោះសាសនាជាម្លប់ ជាទីពឹងដ៏វិសេស ជាទិព្វឱសថសំរាប់កំចាត់រោគពោលគឺ មាន: ទោស: មោហ: និងលោភ: ។

## គ – ពាក្យសួរ

ដូចម្ដេចបានជាមនុស្សម្នាក់ ៗ ឬមនុស្សក្នុងលោកត្រូវកាន់រាប់អានសាសនា បើសាសនា ជាពាក្យទូន្មានឬបណ្ដាំទេ? អ្នកណាជាអ្នកបង្កើតសាសនា? ចុះខ្មែរយើងកាន់សាសនាអ្វី ? អ្វីជាគោលរបស់សាសនា?

---

# មេរៀនទី ៨៥

## អំពីមហាក្សត្រិយ៍

កម្ពុជាជាស្រុកសុទ្ធសាធ មានកិត្តិ៍លើសខ្នាតពន់ប្រមាណ
ព្រោះមានមហាក្សត្រិយ៍ល្អកល្យាណ ទ្រង់បានគ្រងរាជ្យយ៉ាងថ្លៃថ្លា ។

ទ្រង់មានព្រះញាណ ឈ្លាសវាងវៃ ព្រះទ័យសន្ដោសប្រោសមេត្តា
ទ្រង់ថែទាំរាស្ត្រដោយករុណា ដូចកល់បិតារក្សាបុត្រ ។
ហេតុនេះខ្មែរយើងគួរជ្រះថ្លា នឹងមហាក្សត្រាជាម្កុដ
ដំកល់ពជវង្សឲ្យបរិសុទ្ធ បំផុតដល់ពេលកប្បប្រល័យ ។
យើងគួរសង្ឃឹមឲ្យច្រើនណាស់ ដោយយល់ឃើញច្បាស់ថាសព្វថ្ងៃ
យើងមានមហាក្សត្រិយ៍ប្រសើរក្រៃ ទ្រង់មានតេជដៃពេកកន្លង ។
យើងមានមហាក្សត្រិយ៍ជាតិខេមរៈ យើងគួរគារវៈកុំឲ្យហ្មង
ដម្កើងព្រះយសខ្ពស់ចម្បង ក្រៃលែងរាស្ត្រផងជាប្រាកដ ។
យើងកុំប្រទូស្តនឹងព្រះអង្គ គួរផ្ចង់ចិត្តស្ដាប់តាមកំណត់
រដ្ឋធម្មនុញ្ញឲ្យហ្មត់ចត់ នឹងបទមាត្រាច្បាប់គ្រប់ក្រម ។

យុន ឧត្តមប្រីជា ចាប-ពិន (ច្បាប់ប្រដៅកូនចៅខ្មែរ)

## ក- សព្ទពន្យល់

កល្យាណ = (ម.ថ. កល-យ៉ាន) មានលំអដ៏ប្រសើរ គួររាប់អាន ពីរោះ ,

ញាណ = សេចក្ដីដឹង , ប្រាជ្ញា

កប្ប = (ម.ថ. កាប់) កាលដែលតាំងយូរអង្វែង ។

ដល់ពេលកប្បប្រល័យ = រហូតដល់ព្រះអង្គបរមកោដ្ឋ ។

គារវៈ = (ម. ថ. គារៈវៈ) សេចក្ដីគោរព, កិរិយាលំអុតលំទន, ទនលំពោន

វដ្ឋធម្មញ្ញ = (ម. ថ. វ័ត៌ ធៈ ធម្មៈ ន្ញាៈ) ច្បាប់ក្បួនសំរប់នគរ

មាត្រា = ច្បាប់ - គម្ពីរ

## ខ– គំនិត

ព្រះមហាក្សត្រិយ៍ ជាមហាបុរសយ៉ាងថ្កើម ដែលជាទីសង្ឃឹម របស់សាកលជនទូទៅតាំងពីបច្ចុប្បន្ន ហូតដល់អនាគត ។

## គ– សុភាសិត

១.– ស្ដេចមិនឆ្អែតច្បាប់អាណាខេត្ត ប្រាជ្ញមិនឆ្អែតសុភាសិតពុទ្ធដីកា មហាសមុទ្រមិនឆ្អែតស្ទឹងនានា ន័យន៍នេត្រាមិនឆ្អែតគន់រូបគាប់ ។

២.– ព្រះមហាក្សត្រាធិរាជ ទ្រង់អំណាចមរណាក្នុងសង្គ្រាមជ័យ ទើសទ្រង់ កេរ្ដិ៍ប្រសើរជាក្សត្រា ។

(អ៊ុក - ជា)

(លោកនីតិបករណៈ និង អភិនវភាសិត)

## ឃ– ពាក្យសួរ

ឥស្សរជនណា ដែលជាអធិបតីប្រកព្រំនៅនគរកម្ពុជាយើង ?

ព្រោះហេតុអ្វីបានជាព្រះប្រិយមហាក្សត្រិយ៍យើង មានព្រះហឫទ័យមេត្តាសន្ដោសសង្គ្រោះដល់សាកលពលរដ្ឋរបស់ព្រះអង្គ? ចុះបើព្រះអង្គទ្រង់ប្រកបដោយទសពិធរាជធម៌សព្វៗកាលដូច្នេះ តើយើងជាពលរដ្ឋរាស្ត្រនិងមន្ត្រីត្រូវធ្វើការកិច្ចចំពោះព្រះអង្គដូចម្ដេចខ្លះ?

---

## មេរៀនទី ៨៦

## ប្រទេសជាតិ - សាសនា - មហាក្សត្រិយ៍

ជាតិសាសនានិងមហាក្សត្រិយ៍ បីនេះចាត់ជាគោលបី •
សូមជនខ្មែរៈទាំងប្រុសស្រី គប្បីគោរពគ្រប់គ្នា ។
ហៃយុវជនខ្មែរជាតិ ចូរខំខ្មីឃាតរៀនវិជ្ជា
មិនត្រូវដើរលេងល្បែងពាលា ផ្សិតអីការពឹងលើអ្នក ។
ស្រុកយើងថ្កើងយសព្រោះអ្នកនេះ គ្រប់សព្វចំណេះប្រាកដជាក់
តែនេះក្មើក្មើទើទៅទាក់ មិនដឹងរកទវគ្គហៅអ្នកព្រៃ ។
ជាតិខ្មែរកុំស៊ីសាច់ឈាមគ្នា ឃើញរាស្ត្រប្រជាគួរប្រណី
ប្រាយប្រាប់ប្រយោជន៍ដោយមេត្រី នេះដឹងការអីគួរបរបា ។
កុំលេងបៀរប៉ោជួកគាត់ នាំឲ្យវិបត្តិខូចកិរិយា
ខូចទាំងទ្រព្យធនយសសក្ដា ហើយនាំសីមាឲ្យមានទោស ។

ឯករាជ្យត្រូវប្រើតអក្សរជាតិ ហើយលះមារយាទបរពោខា
កុំត្រាប់ប៉ោលគោកចំមែកពោធិ កុំសោត្រូវបេះសព្វភាសា ។

ម៉ុក - ទួន ( ភាសិតោវាទ )

## ក- សព្ទពន្យល់

បុរី= ផែនដី, នគរ, ស្រុក

ល្បែងពាលា= ល្បែងនាំឲ្យវិនាស ដូចល្បែង ស្រី-ស្រា បៀរប៉ោ.... ។

ភារា= រាជធានី, ក្រុង

មេត្រី= អាណិតអាសូរ

វិបត្តិ= អាក្រក់

## ខ- គំនិត

( មើលមេរៀនមុន អំពីជាតិ សាសនា និងអំពីមហាក្សត្រិយ៍ )

## គ- សុភាសិត

១- " បំបែករួមមតិក ,,

តែ – ជុន ( បញ្ហាសង្គម[១] )

(១) សូមរកសៀវភៅនោះមើលទើបដឹងការ ។

៦ – "បំបែករូបសឹមសោយភក្ស"

"បើចង់គ្រង់ភក្ស ត្រូវកលអ្នកប្រាជ្ញ បំបែកសាមគ្គី

"កុំឲ្យជនជាតិ ព្រមព្រៀងគ្នាគ្នី ចង់បានសាមគ្គី

"សឹមឡើងសោយភក្ស" ។

លោកក៉យ - ប៊ុក ( សុភាសិតបាកំង )

## ឃ- ពាក្យសួរ

អ្វីខ្លះ ដែលជាគោលបូរីក្នុងទីនេះ? ដូចម៉េចបានជាលោកហាមល្បែងពាលា ? ក្នុងមេរៀននេះ តាមយោបល់របស់អ្នក ៗ យល់ដូចម្ដេចខ្លះ ?

---

## មេរៀនទី៨៧

### ប្រទេសកម្ពុជា

កម្ពុជាធានីពីព្រេងព្រឹទ្ធ រុងរឿងឫទ្ធិរឹទ្ធិពុតអស្ចារ្យ
ប្រាកដស្ដែងចែងក្នុងពង្សាវតារ មហោឡារលើសលប់គតលោកិយ ។
កេរ្ដិ៍ដំណែលដែលគង់យង់យល់យូរ រូបគំនូរក្បូរក្បាច់ជាប់ដែនដី
ប្រាជ្ញប្រិចក្ខាក់ចុល្អប្រិមប្រិយ ពាក្យបាលីសំស្ក្រឹតជិតសិលា ។
ចារឹកនាមអ្នកសាងដំណាងខ្លួន ប្រាប់ចំនួនសករាជតាមសាសនា
អ្នកមិនគិតពិនិត្យគួរអក្ខរា ទៅជឿថាទេពតាមកសាងឲ្យ ។

ព្រោះប្រាសាទសុទ្ធថ្មល្អហួសគិត   គួរតែទេពនិម្មិតជាអំណោយ
កុំនិយាយយ៉ាងនេះទៀតថ្ងៃក្រោយ   ខ្មែរហ្នឹងហើយធ្វើឲ្យដល់ទេពតា ។
គួរសង្រ្សឹមញញឹមទុកក្នុងចិត្ត   ពីអតីតធ្លាប់ថ្កើនឡើងយ៉ាងណា
តទៅមុខគង់មានជោគជេស្តា   ត្រឡប់សាជាមហាអំណាចខ្ទី ។
ព្រោះពូជខ្មែរក្រៃសែនគតវិត្ត   ថ្វីបើក្លាត់អន់អាប់យ៉ាប់សិរី
គង់តែឡើងថ្កើនយសខ្ពស់បារមី   យូរធាប់ក្តីនឹងបានដូចសព្វា ។
ប្រាង្គសិលា ស្នាដៃខ្មែរកសាង   ជាតិកតាងមិនទាន់បាត់ទៅណា
ល្បីសុសសព្វកពាផែនដែនទ្វីបា   ក្នុងលោកានរណាក៏ស្ញប់ស្ញែង ។
គេបានឮដំណឹងដឹងជាក់ច្បាស់   ជនគ្រប់សាសន៍សុទ្ធសឹងប្រឹងស្វះស្វែង
ធ្វើដំណើរមកមើលដោយខ្លួនឯង   ដល់កន្លែងយល់ស្តែងលែងសង្ស័យ
រូបប្រាសាទប្រសិទ្ធដិតយល់យន់   នៅលើទង់ជាតិខ្មែរតែសព្វថ្ងៃ ។
សំរាប់ដឹងផែនដីល្បីតេជដៃ   ក្នុងសម័យព្រេងព្រឹទ្ធអតីតនាយ ។

មៀវ-នន្ទ (ប្រទេសកម្ពុជានឹងព្រះបាទជ័យវរ្ម័នទី ៧)

## ក- សព្ទពន្យល់

ព្រេងព្រឹទ្ធ = ក្នុងកាលបូរាណ ; ពីដើម.

ឫទ្ធិ = (ម. ជ. រិត) អំណាច

ពង្សាវតារ = (ម. ជ: ពង់ សា វ: ដារ) ដំណើរដែលកត់ទុក ,

កើនក៏តាមលំដាប់នៃវង្សត្រកូល ,    ដំណើរសេចក្ដីអំពីដំណើរនៃវង្សត្រកូល ។

ប្របក្ខ ឬ ប្របក្ស ឬ ប្រត្យក្ស = ( ម. ថ. ប្រប័ក ឬ ប្រត្យ័ក្ស ) ដែលជាក់ច្បាស់ , ច្បាស់ , មែន ; ច្បាស់ប្របក្ខ = គឺ ច្បាស់ដឹងការជាក់ច្បាស់ ។

ជោគបេសា = មានជ័យជំនះឈ្នះសត្រូវ , មានបុណ្យ ។

សប្ធា = ច្បាប់ , ចង , ប៉ុនប៉ង ;

ទ្វីប = ប្រទេសដែលមានជាក់ស្ដែងកណ្ដាលទឹក ( កោះ ) ទីនេះ នគរកម្ពុជាជាពងជាទី មានល្បីក្ដិសព្ទអំពីព្រែននាយ ពីអាស៊ីទ្វីបរហូតដល់ទ្វីបអឺរុប ។

## ១ — គំនិត

យើងត្រូវប្រើសមត្ថភាពឲ្យពេលៗគ្នាឡើង ដើម្បីផ្ដោមផែនគ្នាដល់ការកសាងមាតុប្រទេសឲ្យបានរុងរឿងទាន់កាលសម័យ ; ព្រោះជាតិយើងជាជាតិធ្លាប់មានឥទ្ធិពលតាំងពីបូរាណកាលម្ល៉េះ ។ គោលចារឹក ឬកេរ្តិ៍ដំណែលដែលវង្សវីរបុរសយើងកសាងមិនទាន់បាត់ ឬបាក់បែកនៅឡើយទេ ! ចូរយើងយកជាស្រាប់ ! គ្មានទេវតាឯណាជួយយើងទេ ! មានតែយើងទេ ទើបជួយខ្លួនយើងបាន ។

## គ- សុភាសិត

១ — ប្រទេសណាមិនមានអ្នកប្រាជ្ញ ប្រទេសនោះទុកដូចជាខ្វះព្រលឹងដ៏សំខាន់ ។

ប៊ូ-ប៉ូ (មិត្តសាលាបាលី)

២ — រូបកាយមនុស្សសត្វ តែងទ្រុឌទ្រោមបាត់,
កេរ្តិ៍ឈ្មោះនោះឯង ឋិតថេរគង់លោក
មានជោគជាក់ស្តែង ; យើងគួរប្រឹងប្រែង
.....សាងកេរ្តិ៍ឈ្មោះទុក !!

ឃុន ឧត្តមប្រីជា (ចាប-ពិន.)

## ឃ- ពាក្យសួរ

ដោយហេតុអ្វី, ចារឹកកន្លែងណាខ្លះ, កស្តុតាងណាខ្លះ បានជាហ៊ានថា កម្ពុជាពីដើមមានឈ្មោះល្បីរន្ទឺទូទៅទាំងពិកពលោក ? ចូរក ឧទាហរណ៍ ។ អ្នកយល់ម៉េចខ្លះក្នុងមេរៀននេះ ? ។

ភាគបន្ថែម...

វិចារណកថា...

" មិនធ្វើ មិនខុស "

រ. ប.

# មេរៀនទី ៨៨

## បបក និង ក្អែក

បបកមួយស្គម ទ្រង់ទ្រាយសល់ល្មម
តែស្បែកគ្របឆ្អឹង ជួនជួបក្អែកមួយ
មាឌមាំរឹងប៉ឹង ធាត់ល្អប្រឡឹង
វង្វេងរកផ្លូវ ៗ

នៅមុខបបក ក្អែកនោះបោលបក
ខកហួសជ្រួសផ្លូវ បបកនឹកថា
ប្រហារឥឡូវ គិតបន្តិចទៅ
ទៅជារួញក ៗ

ដោយក្អែកមាឌមាំ មាំមែនត្រណំ
សមខ្លាំងមហិមា ក្រញីក្រញែង
ក្រែងពុំឈ្នះវា ណ្ហើយកាន់ចិត្តជា
សួរវាគួរសម ៗ

— នែសុនខស្រុក ឯងធាត់ទ្រលុក
រាងសោតកុំផ៉ ឯងត្រូវចាំអ្វី?

ឆ្កែងើយថាកុំ　　　　អម្ចាស់ឧត្តម

ឆ្ងល់ក្នុងចិន្តា ៗ

　　លោកឃាត់ទ្វេភាគ　　　　បើលោកព្រមចាក

ចេញពីព្រឹក្សា　　　　តាមខ្ញុំទៅនៅ

ទីដ៏ផៅមនុស្សា　　　　បំណើភោគ្កា

ពោរពាសក្រាសក្រៃ ៗ

　　ក្រិក្រប្រផ្តក់　　　　មុខមាត់ស្ងាំងស្ងក់

គន់ហាក់ជាព្រោយ　　　　បិសាចខ្មោចព្រៃ

យូរថ្ងៃអត់បាយ　　　　តាមខ្ញុំទៅនាយ

បានគោជនា ៗ

　　បបកបានស្តាប់　　　　ទើបសួរប្រញាប់

ទៅសុនខថា　　　　ខ្ញុំត្រូវធ្វើអ្វី

ដើម្បីអាហារ　　　　ឆ្កែថាការងារ

នៅនោះស៊ីគ្មាន　　　　គ្រាន់តែចាំផ្ទះ

ព្រុសឲ្យរហ័ស　　　　យាចកស្ពមទាន

ដនបំឡៃកប្ចូល　　　　ក្នុងគេហស្ថាន

ព្រុសឲ្យដឹងដាន　　　　បានពេញចិត្តម្ចាស់ ៗ

តើអ្នកបានអ្វី
ស្អីជាដំឡៃ
ថ្ងៃខំយាមផ្ទះ
សំណល់សល់ទុក
គ្រប់មុខគ្មានខ្វះ
បើធុនអន់ណាស់
ឆ្អឹងមាន់ឆ្អឹងព្រាប ៗ

ដល់ពេលគេគ្ដា
មិនចាំបរបា
មានជាសម្រាប់
បបកស្ដាប់ជាក់
អួលអាក់ដោយលាក
ខ្លួនធ្លាប់សៀបព្រៀប
ស្ងួតតតដដែក ៗ

ជំ - សារុន ( កម្រងរឿង )

---

## មេរៀនទី ៨៩

### រឿងកុកនឹងបង្កង

និទានមែនមានសត្វកុក ប្រងូវប្រងុក ដើរវែង
ដូចត្រែងស្មោះស្មាន ៗ
ដកពាធាទ្រមប្រាណ ចាប់ត្រីពុំបាន នៅមាត់
ត្រាំងម្នាក់ឯង ៗ

កើតទុក្ខផ្ទប់មុខចម្បែង ទឹកភ្នែកហូរល្ហែង ខ្វល់ទឹកកង្កាញ់ ឥតអាក់ ៗ បង្កងមួយបានយល់ជាក់ រឹងធ្ងល់អន់ក្ស ដើបឡើងស្រែក សួរពីឆ្ងាយ ៗ “បងអើយទុក្ខអ្វីអម្បាយ មានហើសោកស្ដាយ ពីអ្វីស្ដី ប្រាប់ខ្ញុំផង,, ៗ លាក់ថ្វីពីក្ដីសៅហ្មង អញមានបំណង បងអត់អាហារ ឲ្យក្ស័យ ៗ រស់នៅនាំឲ្យអាល័យ ព្រោះជិតដល់ថ្ងៃ ព្រះសុក្រនឹងព្រះ អង្គារ ៗ អង់អាចសាហាវដូចមារ ទន្ទ្រានពានពារ ទំលាយរបរ៉ៅហិនី ៗ កល់យុគទល់ទុក្ខសែនទ្វី ហួតហែងធរណី រាំងក្បៀងដល់ពីរឆ្នាំគត់ ៗ អញនេះមិនអាចទឹងអត់ យល់ត្រឹំសត់ ស្វាប់នៅនឹងមុខបាន ឡើយ ៗ បក្សីបរចាបប់ហើយ ចាប់សោកពុំស្បើយ គួរឲ្យបង្កង ជឿចិត្ត ៗ “បងអើយមេត្តាអាណិត ជួយស្រង់ជីវិត ពួកខ្ញុំឲ្យរួច ពីក្ស័យ,, ៗ មានតែជ្រោះឯនោះនៃ ទើបរួចពីភ័យ ព្រោះមិនចេះរីង ហួតហែង ៗ បង្កងប្រាប់គ្នាឯង មិច្ឆាចម្បែង ដែលដើមខ្លាចក្ដីមរណា ៗ អង្វរសត្វកុកគ្រប់គ្នា កុកព្រមធានា ជួយនាំទៅដល់ជ្រោះជ្រៅ ៗ ពួកត្រីចេញចាកលំនៅ ទំខ្វង់កុកទៅ កាន់ទីដែលខ្លួនពុំស្គាល់ ៗ ក្អើន ចិត្តឥតគិតពិតាល់ រហូតលុះទាល់ បង្កងសុំខ្លួនទៅម្ដង ៗ “ខ្លួនខ្ញុំជាមិត្ត ទឹងបង ម្ដេចមិនចម្លង យកខ្ញុំទៅទីក្សេមក្សាន្ត,, ៗ កុកថា “ប្អូន ឯងកុំភ្ាន,, បង្កងប្រុងប្រាណ ដង្កៀបតោងកបក្សី ៗ

ត្រដាងការស្លាបឃ្លាតខ្លី កុកហិចហើរបី ជំរង់ទៅត្រង់ថ្លដា ។ ទីនោះសុទ្ធតឹងត្រៀបត្រា នៃពួកមច្ឆា ដែលកុកសម្លាប់ពីមុន ។ បង្កងដឹងខ្លួនថាស៊ិន រិះកលដោះគុន ពុតពើសួរកលំនៅ ។ ‘‘បងអើយទីជ្រោះដែលជ្រៅ ដល់កាលណាទៅ ទើបដល់ទីនោះណាបង,, ។

កុកសើចចំអកតបស្នង អញពុំកន្ទុង សាច់ត្រីពុំបង់ស៊ីឡើយ ។ ឥឡូវដល់វេនអាហើយ អញនាំដល់ត្រើយ ល្មមអញទាមទាររង្វាន់ ។ ថាហើយបក្សីចុះជាន់ លើដីគ្រគ្រាន់ គ្រវាត់បង្កងលើថ្ម ។ បង្កងខំប្រឹងក្ដៀបក កុកការគ្រាក្រ រើខ្លួនពុំរួចឡើយណា ។ ចប់ខ្យល់គានតឹងទាក ស្លោស្លឹងនេត្រា ក្សីណក្ស័យជីវ៉ាជាម្ដង ។ គ្រោះល្អួរបងបង្កង ប្រឹងបំកោងខ្លួន ខំផ្ទាត់វាត់ខ្លួនវិលថាន ។ លន់លុះដល់ទឹកប្រៃប្រាណ ហែបហែលកំសាន្ត ទើបផ្សាយដំណឹងពិសី ។

ពីពុតបងកុកអប្រិយ៍ ទំលាយមេត្រី ប្រោកយកទៅធ្វើអាហារ ។ ឥឡូវស្លាប់បង់អសារ អស់ត្រីដឹងការណ៍ រីករាយត្រេកអរពេកក្រៃ ។ គេអាចឈ្នះអស់សត្រូវ យកជ័យដោយផ្លូវ អាវុធប្ដូរដោយបញ្ញា ។ សូម្បីមាឌតូចម្ដេចម្ដា បើឆ្លាតក្លៀវក្លា យក្សផងពុំអាចឈ្នះបាន ។ កុំសិទ្ធទុកចិត្តផ្ញើប្រាណ មេត្រីរាប់អាន ថាកុកវាមិនស៊ីត្រី ។

លោកហាង - យ៉ាន់ (ប្រជុំរឿងល្បើក)

# មេរៀនទី ៩០

## ក្អែកនឹងកញ្ជ្រោង

កាកគតិតែង ដំណាលដំណែន ដំណើរបក្សា
ក្អែកគោកមួយនៅ លើចុងរកា សែនសុខស្ងា -
ពរពិតឥតមោះ ថ្ងៃមួយបក្សី ចេញស្វែងចំណី
តាមភូមិកៀនកោះ ឃើញអ្នកនិគម ហាលនំទឹកដោះ
ក្អែកអរហើរផ្លោះ ចុះចោះចឹកបាន កាន់ស្ទាបហើរស្ទៅ
ដំរង់ត្រង់ទៅ លំនៅស្ថាន ដល់ហើយចុះទំ
ទ្រនំនៃប្រាណ បែរមើលទីឋាន ដានដែនយាត្រា
កាលនោះមានសត្វ កញ្ជ្រោងមួយឆាត់ ស្វែងរកគោក្ដា
មកដល់យល់ក្អែក ទំមែករុក្ខា មាត់ពាំនំប្រា -
កដជាចំណី កញ្ជ្រោងគិតថា អញនឹងបរបា
បញ្ឆោរបក្សី ឲ្យវាហាមាត់ ភ្លាត់ធ្លាក់ចំណី
ជ្រុះមកដល់ដី បានអញវិញណា គិតហើយទើបពោល
ជាពាក្យបញ្ឆោរ ទៅកាន់ក្អែកថា ក្អែកអើយអ្នកក្អែក
រូបឯកសោភា ចំពុះដូចជា ខ័នកែវមរកដ

កោមស្វាបស្រស់ស្រិល  រលោនដូចទិល  រលើបហ្វត់បត់
ចង្កេះសមទ្រង់  ជង្គង់សមបត់  វង់មុខសមមាត់
សមមានលក្ខណា  រូបអ្នកឧត្ដម  បើតាមក្បួនខ្ញុំ
ទំនាយទាយថា  នឹងបានសម្រេច  ជាស្ដេចបក្សា
តែសព្ទសព  ពុំទាន់ប្រត្យក្ស  បើសិនអ្នកស្រែក
ខ្ញុំព្រសម្រែក  សូរសមបំស័ក្ដិ  ខ្ញុំហ៊ានទំនាយ
ទាយថាអ្នកជាក់  បានជាបមប័ក្រ  កំពូលបក្សា ៗ

ក្អែកឡើងអំនួត  ព្រគេសង្កួត  សរសើរអាត្មា
ចង់ឲ្យគេស្ដាប់  សូរសព្ទសព  ទើបឈរឡើងហា
មាត់ស្រែកចេញខ្វី  ឯនំពាំនោះ  ធ្លាក់ពីចំពុះ
ជ្រុះមកដល់ដី  កញ្ជ្រោងស្រុះស្រួល  ទទួលចំណី
ហើយបែរស្រដី  ចំអកបក្សា  ក្អែកអើយចៅក្អែក
អ្នកឯងបែងបែក  ចំណីនេះណា  យើងពេញគាប់ចិត្ត
ដ្បិតអ្នកយល់ថា  យើងជាបោព  ទទួលខាន់ខៅ
ថាហើយចៅក្អែក  ប្រព្រឹត្តនេះឯក  ឥតមានហ្វូងសៅ
អ្នកឯងទៅរក  មកទៀតណាចៅ  ពីថ្ងៃនេះទៅ
យើងបានពឹងផង  ថាស្រេចហើយណា  ប្រឹងចរយាត្រា

ចូលព្រៃដូចប៉ុន    កាកោប់ធំ    ក្រំចិត្តកន្ទួន
ពុំដឹងទំនង    ខ្មោចលងភក្យា ៗ

និទានរឿងនេះ    អញ្ជើញប្រាជ្ញបេះ    ត្រិះមើលកិរិយា
ក្អែកបង់ចំណី    ព្រោះក្តីប្រាថ្នា    ក្នុងបសំសា
ចាយ៉សង្កត ៗ

នរអ្នកណា    មានចិត្តប្រាថ្នា    ចង់ឲ្យគេអួត
នឹងដូចក្អែកខ្មៅ    ត្រូវគេសង្កត    ឆោតឡើងអំនួត
បង់នំឯងអឺយ ៗ

ឧកញ៉ាសុត្តន្តប្រីជា (ឥន្ទ)

---

## មេរៀនទី ៩១

### ប្រាសាទអង្គរ

សូមអធិប្បាយ អំពីដំណើរ ដែលយើងបានដើរ ទៅលេងអង្គរ ៗ
ប្រាសាទបុរាណ ស្អាងស្អាតបវរ នាំចិត្តសាទរ អំណរណាស់សា ៗ
យើងបានមកឃើញ ដូចក្តីប្រាថ្នា បានបរយាត្រា មកលេងសប្បាយ ៗ
គន់មើលសព្វគ្រប់ ប្រសើរពណ្ណរាយ នឹងរកនិយាយ មិនចប់សេចក្តី ៗ
ស្នាដៃយ៉ាងឯក ក្នុងដែនបុរី ល្អពិតឥតបី រកអ្វីផ្ទឹមគ្មាន ៗ

ទោះមើលឆ្ងាយជិត ហាក់ដូចវិមាន ឲ្យតបាកបាន ពីសួគ៌ានាយ ៗ
សុទ្ធតែសិលា ដុំធំពណ្ណរាយ ខ្លះជាបន្ទាយ រុំព័ទ្ធជុំជិត ៗ ក្បាច់ក្បូរ
រចនា រុងរឿងវិចិត្រ ក្យត្រារឹងឫទ្ធិ បានកសាងមក ៗ រីឯក្បាច់នោះ
ប្រៀបដូចពន្លក លូតលាស់ចេញមក ដូចយកទៅបិទ ៗ នៅពេញ
ផ្ទាំង ឆ្លាក់លើថ្មពិត គួរឲ្យរិះគិត តើធ្វើយ៉ាងណា ៗ មានឆ្លាក់ជា
រឿង ច្រើនឥតគណនា ព្រះកេតុមាលា ទេពអប្សរស្រី ៗ ព្រះពុទ្ធរូប
សុទ្ធសឹងពិសី ក្នុងថែវច្រើនខ្លី ឥតបីឧបមា ៗ មានប្រាសាទខ្លះ
ខ្ពស់មហិមា ឧត្តមសោភា ដូចភ្នំកៃលាស ៗ ដើរបន្តិចទៅ ទើបបាន
ឃើញច្បាស់ សក់ពួកក្មេងចាស់ ពេញច្រើនក្រាស់ក្រៃ ៗ ចង់ជា
អម្ចាស ថ្វាយព្រះរត្នត្រ័យ បង់ច្រើនសារសៃ គួរឲ្យស្ញប់ស្ញែង ៗ
ពីលំនៅយើង មើលឃើញជាក់ស្តែង កំពែងខ្វាត់ខ្វែង កំពូលលេច
ថ្កត ៗ ព្រលឹមស្រាងឡើង ហាក់ដូចអណ្តែត ចេញមកត្រែសត
កណ្ដាលវិមាន ៗ ព្រះសង្ឃបីបាត្រ ពីលើចុះឈាន សន្សឹមជំហាន
និមន្តចេញមក ៗ ស្បង់ពណ៌លឿងឆ្អៅ ចាំងនៅពពក ដូចកល់រលក
ករយោផាយផាត់ ៗ កណ្ដាលព្រឹក្សា បៃតង់ស្រងាត់ បីដូចរសាត់
ពីថ្មប្រផេះ ៗ ជូនមានដំរី ដើរធ្វើអេះមេះ មុខថ្មប្រផេះ មិនដឹងធ្វើអ្វី ៗ

ប្រហែលអាស្រ័យ ស្មោតូចទន់ខ្ចី ឬមួយល្មោភដី ក៏សាន្តទេះអេះ ។ ពួកយើងវិលវិញ បេះតែស្រងេះ ស្រងោចអ៊ីម៉េះ រពុកអង្គរ ។ ស្រណោះពន់ពេក រៀបចេញមកឈរ សំឡឹងអង្គរ ពុំមានដាក់ក្អែក ។ ក្តុំបិតផ្តិតក្តួល សឹងឈ្ងួលរហែក បេះដូងស្រើនផ្អែក សឹងស្រកទឹកនេត្រ ។

( នាងក្រមុំ ផ្ទុប - ករុណា )

---

## មេរៀនទី៩២

## គ្រលេងគ្រលោង និងសត្វស្វា

## (បក្សី និងពានរ)

នេះនឹងថ្លាថ្លែង បរបាសំដែងកាលគ្រា ព្រហ្មទត្តរាជា គ្រងបូរីរម្យពារាណសី ។

កាលនោះមែនមាន សកុណាមួយប្រាណ ប្រិមប្រិយ ជាតិជាបក្សី គ្រលេងគ្រលោងសោតណា ។

ធ្វើសំបុកនៅ នាដងព្រៃស្រៅហិមពា សែនសុខស្ថា-ពរពិតឥតមោះមួនមាំ ។

រដូវវស្សា ភ្លៀងធ្លាក់ពសុធាជោកជាំ រងាទន្ទាំ នាំឲ្យសព្វសត្វព្រួយប្រាណ ។

កាលនោះមានស្វា　　រសៅឯកាឥតស្ថាន
ចរចូលត្ពោះថ្កាន　　ប្រញ្ញប្រាណរកទីអាស្រ័យ ៗ
បក្សីឃើញស្វា　　លំបាកអាត្មាច្នោះនៃ
ទើបពោលឆាប់វៃ　　ថាហៃអឺបងពានរ ៗ
ដៃជើងបងឯង　　ប្រាកដជាក់ស្តែងស្ថាពរ
ដូចមនុស្សនិករ　　ម្ដេចមិនធ្វើផ្ទះគ្រាន់ជ្រក ? ៗ
ស្វាឆ្លើយតបថា　　ហៃចៅបក្សាពន្ទូក
ខ្ញុំនឹងស្វែងរក　　ធ្វើផ្ទះគ្រាន់ជ្រកម្ដេចបាន ៗ
ដៃជើងក្បាលខ្ញុំ　　ដូចមនុស្សតូចធំគ្រប់ប្រាណ
ប្រាជ្ញាខ្ញុំគ្មាន　　ធ្វើម្ដេចស.ង់ស្ថានបាននៅ ៗ
គ្រលេងគ្រលោង　　ជាសត្វឃឹតយោងមនុស្សខ្លៅ
ពាលថាលំនៅ　　មិនមានដល់មនុស្សបែបឯង ៗ
ទើបពោលទៀតថា　　រីក្ដីសុខាមិនស្ដែង
ដល់មនុស្សបែបឯង　　ជាសត្វមានចិត្តសាហ៊ ៗ
រប៉ុលរប៉ូច　　រហ័សផ្ទេកផ្ទូបច្នេះណា
ទ្រស្ដមិត្តអាត្មា　　ដូចយ៉ាងបងស្វាឯងហ្នឹង ៗ
នៃពានរអើយ　　គួរកុំកន្ដើយទ្រមឹង

ចូរខំប្រែងប្រឹង ស្មាធ៍ស្មឹងនឹងគេឡើងទៅ ៗ
កុំខ្ជិលប្រអូស លះចិត្តស្រមូសហ្មងសៅ
កុំឲ្យមាននៅ ចូរទៅផ្ញើខ្លួនគ្រាន់ជ្រក ៗ
ពានរគិតថា អាដែងបក្សាពាំមក
ពោលពាក្យបំអក ថាអញជាសត្វទ្រុស្តមិត្ត
ចេះមានតែអញ សំដែងផ្អាលផ្អាញ់ឲ្យពិត
រឿងរ៉ាវទ្រុស្តមិត្ត ឲ្យឃើញប្រច័ក្សដល់វា ៗ
គិតហើយស្ទុះផ្ទាត ផ្ទោះផ្ទាញលោលោតម្នីម្នា
ចាប់ចុងព្រឹក្សា ហោចពោចសម្បុកបក្សី ៗ
ខូចខាតបែកបាក់ ផ្ទុះផ្ទាយខ្ចាយធ្លាក់ដាសដី
សត្វស្វាបលែងស្តី ហើរបុតពីទីនោះបោកង ៗ
លោកអ្នកចូរស្ដាប់ កាន់តាមសណ្ដាប់កុំហ្មង
កុំមោះកន្ទង ពាក្យពិតកាសិតនេះណា ៗ
ចូរចាំឲ្យជាក់ បក្សីធ្លាយធ្លាក់គ្រឹះហា
ព្រោះតែអាត្មា ទូន្មានសត្វស្វាល្ងង់ខ្លៅ ៗ
ពាលស្អប់ឱវាទ បណ្ឌិតវៃឆ្លាតប្រដៅ
ឈើកោងម្លូម៉ៅ តែងស្អប់បន្ទាត់ពេកក្រៃ ៗ

រុយស្អប់បុប្ផា ,　　　ភមរៈបក្សាថ្វាថ្ងៃ

ស្អប់លាមកក្រៃ :　　　គួរស្តាប់ឧបមេយ្យនេះហោង ។

អ៊ុម - សុខ ( កម្ពុជសុរិយា ៥១ )

## សុភាសិត

គេជឿ　　　សឹមនិយាយ

គេស្តាប់　　　សឹមបរិយា

គេស្គាល់គ្នា　　　សឹមធ្វើ ។

ត. ប.

---

Achevé d'imprimer sur les presses de l'IMPRIMERIE CAMBODGIENNE le 10 Avril 1953
Tirage : 1.000 exemplaires
Dépôt légal 2è trimestre 1953

# ខេមរបណ្ណាគារ និង រោងពុម្ព

ផ្ទះលេខ ៣ វិថីពីវ៉ូឡង់ហ៊ូរ៉ី ខាងកើតផ្សារធំថ្មី ភ្នំពេញ សូមថ្វាយប្រគេន ជូនដំណឹង សូមទ្រង់ជ្រាប បានជ្រាប ជ្រាបៗ

ខេមរបណ្ណាគារ ជាបណ្ណាគាររបស់ខ្មែរតែមួយ ដែលធំជាងគេក្នុងកម្ពុជរាជធានី មានសៀវភៅខ្មែរ-បារាំង-អង់គ្លេសព្រមទាំងប្រដាប់ប្រដាឯទៀតៗជាច្រើន សំរាប់គ្រូនិងសិស្សរៀនសូត្រ ឬ មើលកំសាន្ត ៗ

សព្វថ្ងៃកំពុងតែបោះពុម្ពផ្សាយ មានរូបភាពផ្សេងៗនិងសៀវភៅច្រើនមុខ ក្នុងមួយខែមានចេញ៥រឿងរៀងរាល់ខែ មានលក់ដុំនិងលក់រាយ ផ្ញើជូនគ្រប់ខែត្រគ្រប់ស្រុក ព្រមទាំងទទួលជួលបោះពុម្ពអក្សរសាស្ត្រ តាមបំណងលោក-អ្នក គិតថ្លៃថោកគួរសមជូន ៗ

សៀវភៅបោះពុម្ពរួចហើយគឺ:

១– សុភាសិតបារាំង ប្រែជាពាក្យកាព្យខ្មែរ

លោកប៉ាយ-ប៊ុក រៀបរៀង ភាគ១ និងភាគ២ ១ក្បាល ៦៛០០

២– រឿងប្រលោមលោក ភិស្នានៃនាងណាគ្រី

អ្នកស្រី ស៊ុយ-ហៀង រៀបរៀង ១០៛០០

៣– បបញ្ញធម៌ ព្រះមហា ។ .អ៊ុម-ស៊ុម រៀបរៀង ៦រ,០០

៤– ចម្រៀង "ឡាំប៊ូន,, ទំនងចម្រៀងសម័យ បោះពុម្ព លើកថ្មី ៨រ,០០

៥– ប្រវត្តិនៃ "មហាត្មគន្ធី,, លោក រ៉ាយ-ប៊ុក រៀបរៀង ១៥រ,០០

៦– "ពុទ្ធរូបឥតយកហ៊ា,, សម្ដែងអំពីប្រជុំនៃពុទ្ធវចនៈវិទ្យុ ធម្មទេសនាកិត្តមហា ។. ឈឹម-ម៉ឺ ធម្មប្បជ្ជោតោ រៀបរៀង ៥រ,០០

៧– រឿងព្រេងបុរាណផ្សេងៗ ភាគមួយមានរឿងមរណមាតា រឿងរន្ទះ, រឿងមនុស្សដើកក្ដាម ៩រ,០០ មានភាគ ២ ហើយ មានបញ្ចេញភាគត ៗ ទៅទៀតជាលំដាប់

៨– រឿងនាងបទុមវតី ៦រ,០០

៩– រឿងប្រលោមលោក "ស្នឹងក្របាម,, ជារឿងកំសត់ អ្នកស្រី ស៊ុយ-ហៀង រៀបរៀង ១២រ,០០

១០– រឿងព្រេង "សុបិន,, ជារឿងព្រេងពាក្យកាព្យ ៦រ,០០

១១– "ធនញ្ជ័យ" ពាក្យកាព្យទី ១ ៦រ,០០

១២- ជាវិគុណ រឿងព្រេងចិន ទី១-២ ១០៛០០

១៣- មាយើង ស្រកញ្ញើផ្ទុះនឹងស្រីគ្រប់លក្ខណ៍ ៧៛០០

១៤- ផ្ការីកផ្ការោយ អ្នកស្រី ស៊ុយ-ហៀង តែង ១២៛០០

១៥- វត្ថុះពេជ្រ លោក ប៊ុរី-ឆៃ-លាង តែង ៨៛០០

១៦- ពុទ្ធទំនាយ ៥៛០០

១៧- បិនលីគម្ពីរស្វែងរកព្រះបាទធម្មិករាជ ៥៛០០

១៨- ព្រះរាជពង្សាវតារនគរខ្មែរ ១០៛០០

១៩- តំណក់ឈាមលើផ្កាកុលាប ១១៛០០

លោក ប៊ុរី-ឆៃ-លាង តែង

២០- រឿងមកុដពេជ្រ លោក ប៊ុរី-ឆៃ-លាង ទី១- ១០៛០០

ទី២- ១២៛០០

២១- បុល្ឆអភិធម្ម នឹង ប្រស្នាអភិធម្ម ១០៛០០

២២- រឿងអាឡេវ ៧៛០០

២៣- រឿងចៅខ្វាក់ចៅខ្វិន ៨៛០០

២៤- រឿងលោកគ្រូអិកអី

២៥_ មេសូត្រសំរាំង (សំរាប់គ្រូនឹងសិស្ស)

២៦ - ហាត់អានសម័យនិយម

២៧_ Recueil de dictées C.E.P. 12$

២៨_ Recueil de problèmes C.E.P 12$

២៩_ Recueil de rédactions C.E.P 12$

៣០_ Géographie de l'Indochine à paraître

ពុទ្ធសាសនបណ្ឌិត្យ